# របាយការណ៍ស្តីពីការអង្កេតលើការអនុវត្តការងារអប់រំក្រៅប្រព័ន្ធនៃអង្គការក្រៅរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា

**ខែ កុម្ភៈ ឆ្នាំ ២០១៣**

**ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល** (NEP)

**ក្រោមការឧបត្ថម្ភថវិការបស់កម្មវិធី** CapEFA **របស់** UNESCO






លោក **ឡាយ វុត្ថា**  អ្នកសម្របសម្រួលការងារអប់រំក្រៅប្រព័ន្ធ

លោកស្រី **ឈុំ ស៊ីវ៉ុម** មន្ត្រីស្រាវជ្រាវ

លោក **Gordon Conochie** ទីប្រឹក្សាបច្ចេកទេសនៃអង្គការVSOប្រចាំអង្គការNEP



UNESCO
United Nations Educational, Scientific and Cultural Organization

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# មាតិកា


សេចក្តីផ្តើម ..... 3

គោលដៅរបស់ការអង្កេត ..... 4

វិធីសាស្ត្ររបស់ការអង្កេត ..... 6

វិសាលភាពរបស់ការអង្កេត ..... 6

កម្មវិធីអក្ខរកម្ម ..... 17

កម្មវិធីចូលរៀនឡើងវិញ ..... 24

កម្មវិធីសមមូល ..... 25

កម្មវិធីអប់រំបំពេញវិជ្ជា ..... 27

មជ្ឈមណ្ឌលសិក្សាសហគមន៍ ..... 28

បណ្ណាល័យ ..... 31

បន្ទប់អាន ..... 34

វិធីសាស្ត្របង្រៀនក្នុងការអប់រំក្រៅប្រព័ន្ធ ..... 35

លទ្ធផលរកឃើញ និងអនុសាសន៍ ..... 39

ឧបសម្ព័ន្ធ ..... 43

ឧបសម្ព័ន្ធទី ១ ៖ ឈ្មោះរបស់អង្គការក្រៅរដ្ឋាភិបាល ដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ នៅក្នុងឆ្នាំ ២០១២ ..... Error! Bookmark not defined.

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការផ្តល់នូវការអប់រំកម្រិតមូលដ្ឋានប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋគ្រប់រូប និងក្នុងការសម្រេចឱ្យបាននូវគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា (EFA)នៅឆ្នាំ2015 ដោយមិនគិតពីយេនឌ័រ ជាតិសាសន៍ ទីកន្លែងរស់នៅ ឬទ្រព្យធនឬភាពក្រីក្ររបស់មាតាបិតារបស់ពួកគេនោះឡើយ។ អស់ រយៈពេល13ឆ្នាំមកហើយចាប់តាំងពីមានការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិនៅទីក្រុងដាកាប្រទេសសេណេហ្គាល់ឆ្នាំ២០០០ហើយមានការសម្រេចបាននូវវឌ្ឍនភាពជាច្រើនពាក់ព័ន្ធជាមួយនឹងគោលដៅទាំង 6 នៃការអប់រំសម្រាប់ទាំងអស់គ្នា នៅក្នុងប្រទេសកម្ពុជា ។ រដ្ឋាភិបាល ជាមួយនឹងជំនួយពីសហគមន៍អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ កំពុងធ្វើការងារយ៉ាងសស្រាក់ សស្រាំជាមួយគ្នាដើម្បីសម្រេចនូវចំណុចដៅដែលត្រូវបានដាក់ចេញទាំងនេះ ។ ក្រោមការតម្រង់ទិសរបស់ក្របខ័ណ្ឌនៃការអប់រំសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំបង្កើតនូវផែនការយុទ្ធសាស្ត្រ វិស័យអប់រំ (ESP) រយៈពេល5ឆ្នាំ 2009-2013 ដើម្បីជម្រុញវឌ្ឍនភាពនៃការអនុវត្តការងារក្នុងការឈានទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា ។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានរាយការណ៍ពីកិច្ចខិតខំប្រឹងប្រែងសំខាន់ៗជាច្រើននៅក្នុងរយៈពេលកន្លងមកនេះ ដើម្បីដាក់ចេញនូវយុទ្ធសាស្ត្រនានាសំដៅលើកកម្ពស់និងបង្កើនគុណភាពនៃការអប់រំទូទៅ និងជាពិសេស លើកកម្ពស់ជំនាញអក្ខរកម្ម និងរក្សាភាពគង់វង្សក្នុងការសិក្សារបស់ក្រុមដែលជួបប្រទះការលំបាក និងងាយរងគ្រោះ ដែលរស់នៅតាមតំបន់ ជនបទតំបន់ដាច់ស្រយាល និងតំបន់ភ្នំនៅតាមបណ្តោយព្រំដែនរបស់ប្រទេស។ [1]

តែទោះជាយ៉ាងណាក៏ដោយ មានការបង្ហាញឱ្យឃើញច្បាស់ថា គោលដៅនៃការអប់សម្រាប់ទាំងអស់គ្នាមួយចំនួន ពោលគឺគោលដៅទី 3 និងទី 4 មិនសូវទទួលបានការយកចិត្តទុកដាក់ អោយបានជិតដល់ពីសំណាក់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតឡើយ បើធៀបជាមួយនឹងគោលដៅដ៏ទៃទៀតនោះ។ គោលដៅទាំងនេះរួមមាន ៖

**គោលដៅទី 3** ៖ ធ្វើអោយជឿជាក់ថាតម្រូវការរៀនសូត្ររបស់យុវជននិងជនពេញវ័យគ្រប់រូបត្រូវបានផ្តល់អោយតាមរយៈសមធម៌ក្នុងការទទួលបានការនូវការៀនសូត្រមួយសមស្របនិងកម្មវិធីបំនិនជីវិតផ្សេងៗ

**គោលដៅទី 4**៖ សម្រេចបានការ បង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យឱ្យបាន៥០%នៅឆ្នាំ២០១៥ ជាពិសេសចំពោះស្ត្រីព្រមទាំងផ្តល់សមធម៌នៃការអប់រំកំរិតមូលដ្ឋាននិងការអប់រំបន្តដល់យុវជននិងជនពេញវ័យ

---

[1] Department of Non-Formal Education (2008), 'CONFINTEA VI: Rapport national soumis par le gouvernement de/du Cambodge'. MoEYS

ចំនួនអ្នកដែលគ្មានការងារធ្វើ គឺមាន ចំនួន៣ ដង ច្រើនជាងចំនួនមនុស្សពេញវ័ យនៅក្នុងប្រទេសកម្ពុជានេះបើតាមការស្រាវជ្រាវ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ដោយសហការ ជាមួយនឹងអង្គការពលកម្មអន្តរជាតិ (ILO) នៅក្នុងឆ្នាំ 2010[2] ហើយការដោះស្រាយបញ្ហានេះនៅក្នុងប្រទេសកម្ពុជា ត្រូវតែជាអាទិភាពប្រកបដោយនិរន្តរភាព ។ ឱកាសតិចតួចក្នុងការទទួលបានការអប់រំវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញ និងកង្វះជំនួយបន្ទាន់ដល់មនុស្សពេញវ័យ និងក្រុមយុវជនដែលងាយរងគ្រោះដើម្បីជួយពួកគេឱ្យអាចវិលត្រឡប់មករកទីផ្សារការងារវិញ គឺនៅតែជាបញ្ហាដែលមានសារៈសំខាន់បំផុតនៅក្នុងប្រទេសកម្ពុជា[3] ។

ការអប់រំក្នុងប្រព័ន្ធតែមួយគត់មិនអាចបំពេញបានទៅតាមសេចក្តីត្រូវការរបស់មនុស្សពេញវ័យ និងយុវជនទាំងអស់នៅក្នុងសហគមន៍បានឡើយជាពិសេសសម្រាប់ករណីប្រទេសកម្ពុជាតែម្តងដែលមានប្រជាជនវ័យក្មេងមានចំនួនច្រើនហើយមិនសូវមានការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ នៅ តាមតំបន់ជនបទដាច់ស្រយាល និងតំបន់ភ្នំ ។ ឈរលើមូលដ្ឋាននេះ ប្រព័ន្ធអប់រំក្រៅប្រព័ន្ធ ដែលត្រូវបានរាជរដ្ឋាភិបាល កំណត់ថាជាប្រព័ន្ធអប់រំផ្លូវការមួយដែរនោះកំពុងត្រូវបានគេចាត់ទុកថាជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយដើម្បីរួមចំណែកក្នុងសម្រេចឱ្យបាននូវការអប់រំសម្រាប់ទាំងអស់គ្នា និងដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋនូវលទ្ធភាពទទួលបានការអប់រំពេញមួយជីវិត និងជួយកសាងនូវសង្គមមួយដែលពោរពេញដោយការរៀនសូត្រ ប្រកបដោយសមធម៌ យុត្តិធម៌ និងការអភិវឌ្ឍ ។ នាពេលបច្ចុប្បន្ននេះការអប់រំក្រៅប្រព័ន្ធបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអប់រំរបស់ជាតិផ្អែកទៅតាមផែន ការសកម្មភាពជាតិស្តីពីការអប់រំ 2003-2015 ។ សកម្មភាពអប់រំក្រៅប្រព័ន្ធភាគច្រើនត្រូវបានរៀបចំឡើង តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំក្រៅប្រព័ន្ធស្រុក និងមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)ដែលមាននៅក្នុងទូទាំងប្រទេសកម្ពុជាក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់សហគមន៍នៅក្នុងការអភិវឌ្ឍការអប់រំ តាមរយៈការសហការរវាងអង្គការស្ថាប័នដែលពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដ៏ទៃទៀត ។ មានអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ជាច្រើនដែលធ្វើការនៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធដោយផ្តោតលើយុវជននិងមនុស្សពេញវ័យនៅក្នុងប្រទេសកម្ពុជាប៉ុន្តែជារឿយៗអង្គការទាំងនោះមានវិសាលភាពបញ្ហា ចំណុចដៅ ក្រុមគោលដៅនិងសកម្មភាពផ្សេងៗគ្នាហើយបច្ចុប្បន្ននេះគេមិនទាន់ដឹងច្បាស់នៅ ឡើយទេថាតើព័ត៌មានរបស់អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារនៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធត្រូវបានប្រមូល និងគ្រប់គ្រងដោយរបៀបណាដើម្បីអាចរៀបចំផែនការសម្រាប់វិស័យអប់រំក្រៅប្រព័ន្ធនេះឱ្យបានកាន់តែល្អប្រសើរជាងមុន និងមានប្រសិទ្ធភាពនាពេលអនាគតនោះ។

---

[2] Open Editorial Piece by Douglas Broderick, United Nations Resident Coordinator in Cambodia and Jiyuan Wang, Director of the International Labour Organisation (ILO) in Cambodia on 11th August 2011.http://www.un.org.kh/index.php?option=com_content&view=article&id=460:international-youth-day-empowering-cambodias-youth-&catid=47:features&Itemid=88 Accessed on 25th January 2012

[3] EFA Global Monitoring Report (2011), 'The Hidden Crisis: Armed Conflict and Education'. Global Monitoring Report. UNESCCO

ដូច្នេះដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា របស់អង្គការយូណេស្កូ NEP បានធ្វើការអង្កេតមួយលើអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារក្នុងវិស័យអប់រំក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជា ដើម្បីប្រមូលព័ត៌មានស្រដៀងគ្នានឹងព័ត៌មានដែលកំពុងប្រមូលដោយស្ថាប័នរដ្ឋសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំក្រៅប្រព័ន្ធ (NFE-MIS) ។ គោលបំណងរបស់ការអង្កេតនេះ គឺដើម្បីផលិតនូវរបាយការណ៍គ្រប់ជ្រុងជ្រោយមួយ ដោយវិភាគពីវិសាលភាពនិងផល សម្រេចរយៈពេលវែងដែលអ្នកផ្តល់សេវាជាអង្គការក្រៅរដ្ឋាភិបាលមានលើសេវាអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ2012 ។ នេះគឺជាការប៉ុនប៉ងលើកទីមួយ ហើយរបស់អង្គការក្រៅ រដ្ឋាភិបាល ដើម្បីប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យដូចគ្នា នឹងវិធីសាស្ត្រដែលកំពុងប្រើប្រាស់ដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធដោយមានការគាំទ្រពីអង្គការយូណេស្កូ ។

នៅដើមឆ្នាំ 2012 គេមិនដឹងថា នឹងមានការស្រាវជ្រាវនេះឡើយ ដូច្នេះអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការងារនៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធមិនបានដឹងពីរបៀបកត់ត្រាព័ត៌មានតាមបែបផែនឬក្នុងកម្រិតលំអិតដើម្បីឱ្យគេអាចទទួលបានព័ត៌មានពីពួកគេដូចនៅក្នុងការស្រាវជ្រាវនេះឡើយ។ នេះមានន័យថាអង្គការក្រៅរដ្ឋាភិបាលមួយចំនួនមានការលំបាក នៅក្នុងការបង្ហាញព័ត៌មាន ដែលយើងស្នើសុំពីពួកគេ ។

លើសពីនេះតំបន់អនុវត្តគោលដៅជាច្រើនរបស់កម្មវិធីអប់រំក្រៅប្រព័ន្ធមានចម្ងាយឆ្ងាយពីការិយាល័យធំរបស់អង្គការក្រៅរដ្ឋាភិបាលទាំងនេះ ដែលជារឿយៗមានទីតាំងនៅទីរួមខេត្ត។ នេះមានន័យថាការស្រាវជ្រាវរបស់យើងគឺពឹងអាស្រ័យលើការប្រមូលទិន្នន័យដែលធ្វើឡើងដោយការិយាល័យធំនៅក្នុងអង្គការក្រៅរដ្ឋាភិបាលពីកម្មវិធីរបស់ពួកគេនៅមូលដ្ឋាន ម្យ៉ាងវិញទៀត អ្នកប្រមូលទិន្នន័យដែលត្រូវចុះទៅទីតាំង ដាច់ស្រយាលដើម្បីប្រមូលព័ត៌មាន មាន ការលំបាកដោយសារតែពេលវេលានិងថវិកាមានកម្រិត ។ ដោយសារតែបញ្ហាទាំងពីរនេះ យើងគិតថាទិន្នន័យដែលបង្ហាញនេះ ជាទូទៅមិនបានបង្ហាញពីកម្រិត និងវិសាលភាពជាក់ស្តែងនៃសេវាអប់រំក្រៅប្រព័ន្ធដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលឡើយ។

## គោលដៅរបស់ការអង្កេត

NEP មានព័ត៌មានអំពីសមាជិក ដែលបានប្រាប់យើងថា ពួកគេកំពុងធ្វើការងារក្នុងវិស័យអប់រំក្រៅប្រព័ន្ធ ប៉ុន្តែព័ត៌មានលំអិតអំពីថាតើពួកគេធ្វើការងារអ្វីខ្លះនោះ គឺមានលក្ខណៈសង្ខេបខ្លីបំផុត។ លើសពីនេះ NEP មិនមានព័ត៌មានអំពីការងារ ដែលកំពុងធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល ដែលមិនមែនជាសមាជិករបស់NEPឡើយ។ បច្ចុប្បន្ននេះ ពុំមានឯកសារដែលសុក្រឹតអំពីកម្រិត វិសាលភាព និងព័ត៌មាន លំអិតអំពីការងារដែលកំពុងអនុវត្តដោយគ្រប់អង្គការក្រៅរដ្ឋាភិបាលទាំងអស់ នៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធឡើយ។ កង្វះព័ត៌មាននេះក៏មានន័យថា មានកង្វះព័ត៌មានអំពីចំនួនអ្នកទទួលផលពីការងារ ដែលត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលនានា និងរបៀបដែលអ្នកទទួលផលទាំងនេះទទួលបានប្រយោជន៍ឡើយ។

**របាយការណ៍នេះមានគោលបំណង ៖**

១. កំណត់រកអង្គការក្រៅរដ្ឋាភិបាលទាំងអស់នៅក្នុងប្រទេសកម្ពុជាដែលធ្វើការងារក្នុងវិស័យអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ2012

២. រៀបចំជាប្រភេទនិងដាក់តាមកម្មវិធីអប់រំក្រៅប្រព័ន្ធដែលកំពុងអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលក្នុងឆ្នាំ2012

៣. បង្ហាញអំពីទីតាំង និងរយៈពេលរបស់កម្មវិធី ដែលកំពុងអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ក្នុងឆ្នាំ2012

៤. កំណត់ពីចំនួនអ្នកទទួលផលរបស់កម្មវិធី ដែលកំពុងអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ដោយបែងចែកលំអិតទៅតាមភេទ និងយេនឌ័រ

៥. កំណត់គុណវឌ្ឍិ និងបទពិសោធន៍ផ្នែកការអប់រំរបស់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល (រួមទាំងរបស់អ្នកស្ម័គ្រចិត្ត) ដែលចូលរួមផ្តល់សេវាទាំងនេះ

៦. ប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យដូចគ្នា នឹងវិធីសាស្ត្រដែលប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីតម្រឹមទៅតាមប្រព័ន្ធរដ្ឋាភិបាល និងពង្រឹងមុខងាររបស់ក្រសួង តាម រយៈការផ្តល់ជាអនុសាសន៍

៧. ចែករំលែក និងពិភាក្សាពីលទ្ធផលនៃការសិក្សា នៅក្នុងចំណោមអ្នកធ្វើការងារពាក់ព័ន្ធនឹងការអប់រំក្រៅប្រព័ន្ធ សំដៅលើកកម្ពស់ការសម្របសម្រួល

**ផលសម្រេចដែលរំពឹងទុកៈ**

NEP ចង់សម្រេចនូវផលសម្រេចចំនួន 3 ចេញពីការធ្វើការអង្កេតនេះ ៖

i. នឹងមានការសហការកាន់តែច្រើនជាងមុន ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ដោយសារតែគេនឹងដឹងពីគ្រប់អង្គការស្ថាប័នទាំងអស់ ដែលចូលរួមបំពេញការងារក្នុងវិស័យអប់រំក្រៅប្រព័ន្ធ និងទីតាំងរបស់អង្គការស្ថាប័នទាំងអស់ នោះ។ នេះនឹងនាំឱ្យមានការបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន។

ii. NEP នឹងអាចផ្តល់ការគាំទ្រ ដល់ការអង្គការធ្វើការងារក្នុងវិស័យអប់រំក្រៅប្រព័ន្ធ ដែលគេមិនធ្លាប់ស្គាល់ពីមុនមក

iii. រដ្ឋាភិបាលនៅថ្នាក់ជាតិ នឹងមានព័ត៌មានកាន់តែច្រើនជាងមុនអំពីការអនុវត្តការងាររបស់ អង្គការក្រៅរដ្ឋាភិបាលនៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធដែលនឹងត្រូវបានគេយកទៅប្រើប្រាស់ សម្រាប់រៀបចំផែនការសម្រាប់វិស័យនេះ ដោយមានការសម្របសម្រួលបានល្អ

## វិធីសាស្ត្រនៃការអង្កេត

NEPបានប្រើប្រាស់កម្រងសំណួរចំនួន5 ដែលទើបតែបង្កើតឡើងកាលពីពេលថ្មីៗនេះដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធសម្រាប់NFE-MISដែលធានាថាទិន្នន័យដែលប្រមូលបាននឹងមានភាពស៊ីគ្នានិងស្របគ្នាជាមួយនឹងព័ត៌មាន ដែលប្រមូលពីអ្នកផ្តល់សេវាអប់រំក្រៅប្រព័ន្ធរបស់រដ្ឋ។ កម្រងសំណួរទាំង 5 រួមមាន ៖

១. កម្រងសំណួរសម្រាប់កម្មវិធីអក្ខរកម្ម/ ជំនាញមុខរបរ

២. កម្រងសំណួរសម្រាប់កម្មវិធីចូលរៀនឡើងវិញ

៣. កម្រងសំណួរសម្រាប់កម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ

៤. កម្រងសំណួរសម្រាប់កម្មវិធីអប់រំពេញបំពេញវិជ្ជា

៥. កម្រងសំណួរសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍/បណ្ណាល័យ /បន្ទប់អាន

NEP បានកំណត់រកអង្គការក្រៅរដ្ឋាភិបាលចំនួន 8 ដែលធ្វើការងារនៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធដើម្បីជួយប្រមូលទិន្នន័យឱ្យ NEP នៅតាមបណ្តាខេត្តរបស់ពួកគេ ឬខេត្តដែលនៅជុំវិញ។ នេះគឺជាវិធីសាស្ត្រដែលយើងចង់បានដោយសារតែអង្គការក្រៅរដ្ឋាភិបាលដឹងពីប្រធានបទនេះច្បាស់ ដែលជួយឱ្យពួកគេធ្វើការបកស្រាយការឆ្លើយតបកាន់តែសុក្រឹតបន្ថែមទៀត។ប៉ុន្តែយើងចាំបាច់ត្រូវជួលអ្នកប្រមូលទិន្នន័យ៨នាក់ដើម្បីសម្ភាសអង្គការក្រៅរដ្ឋាភិបាល នៅក្នុងខេត្តកំពង់ចាមនិងកំពង់ធំ រតនគិរីនិងក្រចេះ បាត់ដំបងនិង ពោធិសាត់ ព្រះសីហនុនិងរាជធានីភ្នំពេញ។ គ្រប់អ្នកប្រមូលទិន្នន័យទាំងអស់សុទ្ធតែបាន ទទួលការបណ្តុះបណ្តាលដែលមានដាក់បញ្ចូលបទបង្ហាញពីតំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា ដែលជាអ្នកបង្កើតកម្រងសំណួរខាងលើ។

## វិសាលភាពរបស់ការអង្កេត

តាមរយៈការធ្វើការងារជាមួយនឹងសមាជិកNEPនិងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារក្នុងវិស័យអប់រំក្រៅប្រព័ន្ធ NEP បានកំណត់រកឃើញអង្គការក្រៅរដ្ឋាភិបាលចំនួន110អង្គការដែលត្រូវបានគេចាត់ទុកថាកំពុងផ្តល់សេវាអប់រំក្រៅប្រព័ន្ធ។ អង្គការក្រៅរដ្ឋាភិបាលទាំងនេះមានទីតាំងនៅក្នុងខេត្តចំនួន 15។ បើទោះបីជាមានការខិតខំប្រើប្រាស់សមាជិករបស់យើង និងក្រុមការងារវិស័យអប់រំនៅថ្នាក់ខេត្ត ដើម្បីរកអង្គការក្រៅរដ្ឋាភិបាលដែលមានសក្តានុពលក្នុងការផ្តល់សេវាអប់រំក្រៅប្រព័ន្ធ នៅក្នុងខេត្តនៅសល់ទាំង 9 ក៏ដោយពុំមានអង្គការក្រៅរដ្ឋាភិបាលណាផ្សេងទៀតត្រូវបានរកឃើញឡើយ ដូច្នេះហើយ NEP សម្ភាសតែអង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តចំនួន15 តែប៉ុណ្ណោះ ពោលគឺខេត្តបាត់ដំបង កំពត កំពង់ចាម កំពង់ធំ កណ្តាល ក្រចេះ មណ្ឌលគិរី

ភ្នំពេញ ព្រះសីហនុ ព្រៃវែង ពោធិសាត់ រតនគិរី សៀមរាប ស្វាយរៀង និងតាកែវ។ ក៏ប៉ុន្តែក្នុងអំលុងពេលចុះធ្វើការសិក្សាស្រាវជ្រាវអង្កេតនេះយើងទទួលបាន ព័ត៍មានពីខេត្តមួយបន្ថែម ទៀតគឺខេត្តបន្ទាយមានជ័យ ដូចនេះសរុបទាំងអស់មាន16រាជធានីខេត្តដែលយើងបានប្រមូល ។ ហើយគ្រប់អង្គការទាំងអស់ត្រូវបានស្នើសុំអោយផ្តល់ព័ត៏មានអំពីការអនុវត្ត កម្មវិធីអប់រំក្រៅប្រព័ន្ធរបស់គេតែនៅក្នុងឆ្នាំ២០១២ប៉ុណ្ណោះ ។

## កម្រិតចូលរួមក្នុងវិស័យអប់រំក្រៅប្រព័ន្ធ និងកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាល

បើទោះបីជាអង្គការក្រៅរដ្ឋាភិបាលទាំង 110 អង្គការដែលត្រូវបានកំណត់រកឃើញថាអាចជាអង្គការដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធក៏ដោយក្រោយពីបានសម្ភាសជាមួយពួកគេរួចមកមានអង្គការក្រៅរដ្ឋាភិបាលតែ 48 អង្គការតែប៉ុណ្ណោះដែលអាចផ្តល់ព័ត៍មានលំអិតអំពីកម្មវិធីរបស់ពួកគេនៅក្នុងឆ្នាំ 2012 ។ យើងគិតថាភាពមិនច្បាស់លាស់ពាក់ព័ន្ធជាមួយនឹងអ្វីដែលគួរនិងអ្វីដែលមិនគួរបែងចែកថាជាសេវាអប់រំក្រៅប្រព័ន្ធអាចនាំឱ្យមានចំនួននេះ ដែលបង្ហាញមិនដល់ចំនួនជាក់ស្តែងរបស់អង្គការក្រៅ រដ្ឋាភិបាលដែលកំពុងផ្តល់សេវាអប់រំក្រៅប្រព័ន្ធ ។ **<u>ឧទាហរណ៍</u>** មានភាពមិនច្បាស់លាស់អំពីថាតើកម្មវិធី អក្ខរកម្មមួយដែលចូលរួមដោយកុមារក្នុងនិងក្រៅសាលាគួរចាត់ទុកថាជាសេវាអប់រំក្រៅប្រព័ន្ធដែរឬទេ ។ ការលំបាកនៅក្នុងការបែងចែកឱ្យបានច្បាស់លាស់រវាងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ធ្វើឱ្យគេកាន់តែ មានការលំបាក ក្នុងការកំណត់រកអង្គការក្រៅរដ្ឋាភិបាលហើយធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលមួយចំនួនមានភាពមិនច្បាស់លាស់ថាតើខ្លួនកំពុងផ្តល់សេវាអប់រំក្រៅប្រព័ន្ធឬអត់នោះ។ ចំណុចមួយបន្ថែមទៀតគឺថា អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានប្រាប់អ្នកស្រាវជ្រាវ ថា ពួកគេមានកម្មវិធីតិចតួចតែប៉ុណ្ណោះនៅក្នុងឆ្នាំ2012 ដោយសារតែកង្វះថវិកា ដើម្បីបន្តសកម្មភាពអប់រំក្រៅប្រព័ន្ធចាប់តាំងពីឆ្នាំ2011 មក។

ខាងក្រោមនេះ គឺជាចំនួនអង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់នូវប្រភេទកម្មវិធីនីមួយៗនៃកម្មវិធីអប់រំ ក្រៅប្រព័ន្ធ ហើយឈ្មោះអង្គការក្រៅរដ្ឋាភិបាលទាំងនេះអាចរកឃើញ នៅក្នុងឧបសម្ព័ន្ធទី 1។

**តារាងទី 1** ៖ ចំនួនអង្គការក្រៅរដ្ឋាភិបាល ដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយបែងចែកតាមប្រភេទ

| ប្រភេទកម្មវិធី | ចំនួនអង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តកម្មវិធី | ភាគរយនៃគ្រប់អង្គការក្រៅរដ្ឋាភិបាលទាំងអស់ដែលផ្តល់សេវាអប់រំក្រៅប្រព័ន្ធ |
|---|---|---|
| អក្ខរកម្ម | 19 | 40% |
| ជំនាញការងារ | 23 | 48% |

| | | |
|---|---|---|
| ចូលរៀនឡើងវិញ | 4 | 8% |
| សមមូល | 7 | 15% |
| បំពេញវិជ្ជា | 1 | 2% |
| មជ្ឈមណ្ឌលសិក្សាសហគមន៍ | 19 | 40% |
| បណ្ណាល័យ | 9 | 19% |
| បន្ទប់អាន | 3 | 6% |

* អង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធច្រើនជាង ១ ប្រភេទ ដូច្នេះភាគរយទាំងនេះមិនគួរបូក ចូលគ្នាបានដល់ 100% ប៉ុណ្ណោះទេ

ក្នុងចំណោមប្រភេទកម្មវិធីផ្សេងៗពីគ្នា ប្រភេទកម្មវិធីដែលអង្គការក្រៅរដ្ឋាភិបាលមួយអនុវត្តញឹកញាប់ជាងគេគឺកម្មវិធីជំនាញមុខរបរ ។ **48%** នៃអង្គការក្រៅរដ្ឋាភិបាលចំនួន 48 ដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្តល់នូវកម្មវិធីជំនាញមុខរបរនេះ។ ប្រភេទកម្មវិធីពេញនិយមជាងគេបន្ទាប់ គឺកម្មវិធីអក្ខរកម្ម ដោយមានអង្គការក្រៅរដ្ឋាភិបាល **40%** អនុវត្តកម្មវិធីនេះ។ ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលច្រើនតែមានកម្មវិធីអក្ខរកម្មក្នុងចំនួនច្រើនជាងកម្មវិធីជំនាញមុខរបរ ។

តាមរយៈការស្រាវជ្រាវរបស់យើងនេះយើងបានរកឃើញថាមានកម្មវិធីអប់រំក្រៅប្រព័ន្ធចំនួន**383** កម្មវិធីដែលត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលនៅក្នុងឆ្នាំ **2012** ដូចដែលបង្ហាញនៅក្នុងតារាងខាងក្រោម។ ក្នុងចំណោមកម្មវិធីទាំង **383** នេះ **168** កម្មវិធីជាកម្មវិធីអក្ខរកម្ម (44%) និង**119** (31%) ជាកម្មវិធីជំនាញមុខរបរ ។

**តារាងទី ២ ៖** ចំនួនកម្មវិធីអប់រំក្រៅប្រព័ន្ធ បែងចែកទៅតាមប្រភេទកម្មវិធី




ប្រសិនបើអង្គការក្រៅរដ្ឋាភិបាលមួយកំពុងអនុវត្តកម្មវិធីអក្ខរកម្ម ពួកគេផ្តល់នូវកម្មវិធីអក្ខរកម្មគិតជាមធ្យម 10.4 ប៉ុន្តែមធ្យមភាគសមមូលសម្រាប់ជំនាញមុខរបរគឺ 5.4 កម្មវិធី ។ សម្រាប់អង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តកម្មវិធីសមមូល មធ្យមភាគក្នុងអង្គការក្រៅរដ្ឋាភិបាលមួយគឺតិចជាង 4 កម្មវិធីសមមូលសម្រាប់អង្គការក្រៅរដ្ឋាភិបាលមួយ។

ចំនួនដែលបានបង្ហាញពីការផ្តល់កម្មវិធីអប់រំក្រៅប្រព័ន្ធរបស់រដ្ឋាភិបាលសម្រាប់ឆ្នាំ2012ត្រូវបានទទួលនៅក្នុងកិច្ចប្រជុំមួយជាមួយនឹងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ កាលពីថ្ងៃទី 29 ខែ មករា ឆ្នាំ 2013 ហើយត្រូវបានយកមកបង្ហាញខាងក្រោមដែលបង្ហាញឱ្យឃើញពីកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់នាយកដ្ឋានចំនួន **3217** កម្មវិធី។ បូកបន្ថែមចំនួននេះជាមួយនឹងកម្មវិធីចំនួន **383** ដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលមានកម្មវិធីអប់រំក្រៅប្រព័ន្ធក្រៅប្រព័ន្ធចំនួន **3600** នៅក្នុងប្រទេសកម្ពុជាដោយអង្គការក្រៅរដ្ឋាភិបាលអនុវត្ត **11%** នៃគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធទាំងអស់។

**តារាងទី ៣** ៖ ចំនួនកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់រដ្ឋាភិបាលនៅក្នុងឆ្នាំ 2012




ក្រាហ្វខាងលើបង្ហាញថាព័ត៌មាន អំពីការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធដែលផ្តល់ដោយរដ្ឋាភិបាលគឺខុសប្លែកពីការអនុវត្តរបស់អង្គការក្រៅរដ្ឋាភិបាល។ __**ឧទាហរណ៍:**__ **75%**គ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធទាំងអស់របស់អង្គការក្រៅរដ្ឋាភិបាលផ្តោតលើអក្ខរកម្មឬជំនាញមុខរបរ ប៉ុន្តែមានតែកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់រដ្ឋាភិបាលត្រឹម **38%** ប៉ុណ្ណោះដែលផ្តោតលើអក្ខរកម្ម ឬជំនាញ មុខរបរនេះ ។ កម្មវិធីពេញនិយមបំផុតដែលអនុវត្តដោយរដ្ឋាភិបាល គឺកម្មវិធីចូលរៀនឡើងវិញ ដែលស្មើនឹង **43%** នៃកម្មវិធីអប់រំក្រៅប្រព័ន្ធទាំងអស់របស់រដ្ឋាភិបាល ។

កម្មវិធីសមមូល គឺជាកម្មវិធីដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលតែប៉ុណ្ណោះ។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា មិនទាន់បានបញ្ចប់កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិនៅឡើយហើយក៏មិនទាន់បានធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សាសម្រាប់កម្មវិធីអក្ខរកម្មដែរ ។ លើសពីនេះពុំមានលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ការណែនាំអំពីការជ្រើសរើសគ្រូសមមូលដែរ ។ អង្គការក្រៅរដ្ឋាភិបាលនានាមិនមានភាពប្រាកដប្រជាអំពីអ្នកដែលពួកគេគួរជួលឱ្យមកបង្រៀនថ្នាក់សមមូល ហើយនិងសៀវភៅព្រមទាំងកម្មវិធីសិក្សាដែលគួរយកមកប្រើប្រាស់ឱ្យបានប្រាកដនោះឡើយ។ ទាំងនេះអាចជាមូលហេតុដែលរួមចំណែកធ្វើឱ្យកម្មវិធីសមមូលមានចំនួនតិចតួច ។

បើទោះបីជាមានកម្មវិធីចូលរៀនឡើងវិញជាច្រើនរបស់រដ្ឋាភិបាលក៏ដោយ មានកម្មវិធីចូលរៀនឡើងវិញតិចតួចតែប៉ុណ្ណោះ ដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល។ នេះអាចដោយសារតែគោលការណ៍ណែនាំដែលពុំមានភាពបត់បែន ដែលកំណត់ពីចំនួនសិស្សពិតប្រាកដនៅក្នុងថ្នាក់ និងក្រុមគោលដៅដែលពាក់ព័ន្ធ។ ឧទាហរណ៍:នៅតាមតំបន់ទីក្រុងឬតំបន់ដែលមានអត្រាបោះបង់ចោលការសិក្សាខ្ពស់ទំហំថ្នាក់ចូលរៀនឡើងវិញគួរមានសិស្សពី 20ដល់ 25 នាក់។ នៅតាមតំបន់ ឬមូលដ្ឋានដាច់ស្រយាល ដែលមានអត្រាបោះបង់ចោលការ

សិក្សាទាប គួរមានសិស្សពី 15-20នាក់ សម្រាប់ថ្នាក់នីមួយ ។ វាអាចជាការលំបាកសម្រាប់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនក្នុងការរៀបចំថ្នាក់ដែលមានទំហំបែបនេះ។

ក្នុងចំណោមកម្មវិធីចូលរៀនឡើងវិញទាំង10ដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាលមាន 9 កម្មវិធីដែលជាកម្មវិធីថ្នាក់ផ្ទួប ។ ដូចដែលនឹងលើកយកមកពិភាក្សានៅក្នុងផ្នែកខាងក្រោម អំពីកម្មវិធីចូលរៀនឡើងវិញអាចថាកម្មវិធីចូលរៀនឡើងវិញរបស់រដ្ឋាភិបាលមិនផ្តោតតែលើកុមារក្រៅសាលាឡើយប៉ុន្តែផ្តោតលើសិស្សដែលរៀនបំប៉នបន្ថែម មុនពេលដែលពួកគេប្រឡងម្តងទៀត ដើម្បីឡើងទៅថ្នាក់បន្ទាប់។

ដោយសារតែមានការប្រែប្រួលខ្លាំងនៃការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធទៅតាមប្រភេទនីមួយៗការអនុវត្តកម្មវិធីទាំងនេះមានលក្ខណៈខុសៗគ្នា ក្នុងចំណោមខេត្តនានាក្នុងប្រទេសកម្ពុជា។ ការប្រែប្រួលនេះអាចកើតឡើងដោយសារតែកត្តាជាច្រើន ៖

- តម្រូវការខុសៗគ្នាសម្រាប់កម្មវិធីអប់រំក្រៅប្រព័ន្ធរវាងខេត្តមួយ និងខេត្តមួយទៀត
- ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធខុសៗគ្នា ដោយរដ្ឋាភិបាល

ហេតុផលមួយក្នុងចំណោមហេតុផលទាំងពីរនេះ គឺជាមូលហេតុសមស្របដែលនាំឱ្យមានភាពខុសប្លែកគ្នានៃការអនុវត្តកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាលដោយសារតែពួកគេប្រតិកម្មតបទៅនឹងតម្រូវការសេវាឬការផ្តត់ផ្គង់សេវាដែលមានស្រាប់ ។ ប៉ុន្តែវាអាចថាមានការផ្តល់សេវាខុសៗគ្នាដោយអង្គការក្រៅរដ្ឋាភិបាលទៅតាមទីតាំងជាក់លាក់ដែលជាគោលដៅរបស់អង្គការក្រៅរដ្ឋាភិបាលឬអ្នកផ្តល់ជំនួយខណៈពេលដែលខេត្តផ្សេងទៀតដែលមានតម្រូវការស្រដៀងគ្នានេះមិនបានទទួលការយកចិត្តទុកដាក់ ។ ព័ត៌មានដែលទទួលបានពីការអង្កេតនេះគួរយកទៅដាក់បញ្ចូលជាមួយនឹងព័ត៌មានដែលប្រមូលដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការស្រាវជ្រាវថាតើទីតាំងមួយចំនួន មានតម្រូវការសេវាច្រើនជាងទីតាំងផ្សេងទៀតដែរឬទេ ។

**តារាងទី ៤ ៖** ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធបែងចែកទៅតាមខេត្ត

| | សរុប | ជំនាញការងារ | អក្ខរកម្ម | ម.ស.ស/ បណ្ណាល័យ / បន្ទប់អាន | បំពេញវិជ្ជា | ចូលរៀនឡើងវិញ | សមមូល |
|---|---|---|---|---|---|---|---|
| បន្ទាយមាន-ជ័យ | 2 | 2 | | | | | |
| បាត់ដំបង | 38 | 24 | 4 | 2 | | 5 | 3 |
| កំពង់ចាម | 1 | | | 1 | | | |
| កំពត | 15 | | 15 | | | | |
| កណ្តាល | 8 | 8 | | | | | |
| កំពង់ធំ | 17 | | 16 | | | 1 | |
| ប៉ៃលិន | 1 | 1 | | | | | |
| ភ្នំពេញ | 55 | 27 | 7 | 9 | | 0 | 12 |
| ព្រះវិហារ | 1 | 1 | | | | | |
| ព្រះសីហនុ | 35 | | 12 | 9 | 6 | 4 | 4 |
| ព្រៃវែង | 23 | 10 | 2 | 3 | | | 8 |
| ពោធិសាត់ | 28 | 4 | 24 | | | | |
| រតនគិរី | 68 | | 58 | 10 | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សៀមរាប | 7 | 1 | 1 | 4 | | 0 | 1 |
| ស្វាយរៀង | 75 | 29 | 33 | 13 | | | |
| តាកែវ | 9 | 7 | 1 | 1 | | | 0 |

*ដោយសារតែមានចន្លោះតិចតួច និងដោយសារការបង្ហាញ មជ្ឈមណ្ឌលសិក្សាសហគមន៍ បន្ទប់អាន និងបណ្ណាល័យ ត្រូវបានដាក់បញ្ចូលគ្នាតែមួយ នៅក្នុងតារាងនេះ ប៉ុន្តែកម្មវិធីនីមួយៗមានផ្នែករបស់វា ដែលផ្តល់នូវព័ត៌មានលំអិត នៅក្នុងរបាយការណ៍នេះ។

តារាងខាងលើបង្ហាញថា ខេត្តស្វាយរៀងមានកម្មវិធីអប់រំក្រៅប្រព័ន្ធច្រើនជាងគេដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល បន្ទាប់មកគឺខេត្តរតនគិរី និងរាជធានីភ្នំពេញ។ នេះមិនមែនជាអ្វីដែលគេមិនបានរំពឹងទុកជាមុននោះទេ ដែលថាមានការផ្តោតការយកចិត្តទុកដាក់លើខេត្តស្វាយរៀង និងខេត្តរតនគិរីនោះដោយសារតែខេត្តស្វាយរៀង គឺជាខេត្តក្រីក្រជាងគេទីពីរនៅក្នុងប្រទេសកម្ពុជា ដោយមានអត្រាអនក្ខរភាពខ្ពស់ហើយខេត្តរតនគិរីមានអត្រាអក្ខរកម្មទាបប្រហែលជា 46%[4] តែប៉ុណ្ណោះហើយក៏ជាខេត្តដែលមានប្រជាជនជនជាតិភាគតិចខ្ពស់ហើយដែលភាសាកំណើតរបស់ពួកគេមិនមែនជាភាសាខ្មែរ ។ 52% នៃកម្មវិធីអប់រំក្រៅប្រព័ន្ធទាំងអស់របស់អង្គការក្រៅរដ្ឋាភិបាល មានទីតាំងតែនៅក្នុងខេត្តបីតែប៉ុណ្ណោះ - ស្វាយរៀង រតនគិរី និងរាជធានីភ្នំពេញ។ ប៉ុន្តែខេត្តស្វាយរៀងនិងរតនគិរីពុំមានកម្មវិធីបំពេញវិជ្ជា ចូលរៀនឡើងវិញ ឬសមមូលដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាលឡើយ។

ខេត្តសៀមរាប គឺជាខេត្តក្រីក្រជាងគេ ប៉ុន្តែមានកម្មវិធីអប់រំក្រៅប្រព័ន្ធត្រឹមតែ 7កម្មវិធីតែប៉ុណ្ណោះដែលក្នុងចំណោមកម្មវិធីទាំងនេះ មានកម្មវិធីតែពីរប៉ុណ្ណោះ ដែលពាក់ព័ន្ធជាមួយនឹងអក្ខរកម្ម និងជំនាញ មុខរបរ ហើយមានកម្មវិធី 4 ដែលជាកម្មវិធីមជ្ឈមណ្ឌលសិក្សាសហគមន៍ឬបណ្ណាល័យ។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡានិងអង្គការក្រៅរដ្ឋាភិបាលប្រហែលជា ត្រូវពិចារណានិងធ្វើការវិភាគថាតើមានខេត្តណាខ្លះដែលមានកម្មវិធីអប់រំក្រៅប្រព័ន្ធច្រើនជាងគេ និង ថាតើមានខេត្តណាខ្លះឬតំបន់ណាខ្លះដែលមិនមានកម្មវិធីអប់រំក្រៅប្រព័ន្ធត្រូវបានអនុវត្តដោយរដ្ឋាភិបាលឬដោយអង្គការក្រៅរដ្ឋាភិបាលហើយដែលគួរត្រូវបានផ្តល់អាទិភាពច្រើនជាងគេ។ការបញ្ចូលទិន្នន័យនិងវិភាគអោយបានគ្រប់ជ្រុងជ្រោយនេះអាចជួយធ្វើឱ្យការរៀបចំផែនការ ការអនុវត្ត និង ការផ្តោតក្រុមគោលដៅនិងធនធាននានាកាន់តែមានភាពប្រសើរជាងមុន។

[4] General Population Census 2008

## ប្រភេទកម្មវិធីអប់រំក្រៅប្រព័ន្ធ

លទ្ធផលនៃការអង្កេតនេះបង្ហាញថាប្រភេទកម្មវិធីអប់រំក្រៅប្រព័ន្ធដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលគឺស្រដៀងគ្នានឹងសមាសភាគផ្តល់សេវានៅក្នុងគោលនយោបាយស្តីពីកម្មវិធីសិក្សាអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលចេញនៅក្នុងឆ្នាំ 2002[5] ដែរ ។ ប៉ុន្តែភាពខុសប្លែកគ្នារវាងប្រភេទកម្មវិធីផ្សេងៗទាំងនេះអាចមានកម្រិតតិចតួចបំផុត ហើយអាច នាំអោយមានភាពមិនច្បាស់លាស់ដែលនាំឱ្យគេពិបាកនឹងកំណត់ ថាតើកម្មវិធីអប់រំក្រៅប្រព័ន្ធមួយ ជាកម្មវិធសមមូល ឬកម្មវិធីបំពេញវិជ្ជា។ នេះនាំឱ្យមានការលំបាកមួយចំនួននៅក្នុងពេលប្រមូលទិន្នន័យដោយសារតែតំណាងអង្គការក្រៅរដ្ឋាភិបាលឬអ្នកប្រមូលទិន្នន័យអាចមិនយល់ច្បាស់អំពីសមាសភាគសំខាន់ៗផ្សេងគ្នារបស់កម្មវិធីអប់រំក្រៅប្រព័ន្ធ ។ យើងរកឃើញថាជួនកាលកម្មវិធីនានាត្រូវបានអនុវត្តលាយឡំគ្នា ទាំងការប្រើប្រាស់ឯកសារ ទាំងជាមួយនឹងក្រុមគោលដៅ ។

យើងក៏បានរកឃើញថា មានកម្មវិធីជាច្រើន ដែលកំពុងអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ដែលគួរចាត់ទុកថាជាកម្មវិធីអប់រំក្រៅប្រព័ន្ធ ប៉ុន្តែមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីពិពណ៌នាអំពីកម្មវិធីអប់រំក្រៅប្រព័ន្ធនៅក្នុងគោលនយោបាយអប់រំក្រៅប្រព័ន្ធផ្លូវការ ។ នេះធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលកាន់តែមានការលំបាកក្នុងការយល់ថាតើសេវារបស់ពួកគេស្ថិតក្រោមប្រភេទមួយណានៃកម្មវិធីអប់រំក្រៅប្រព័ន្ធឬថាតើសេវារបស់ពួកគេគឺជាសេវាអប់រំក្រៅប្រព័ន្ធដែរឬអត់នោះ ។ នេះមានន័យថាអង្គការក្រៅរដ្ឋាភិបាលមួយចំនួនអាចកំពុងអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ប៉ុន្តែមិនចាត់ទុកខ្លួនឯងថាជាអ្នកអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។ អង្គការ ក្រៅរដ្ឋាភិបាលមួយចំនួនអាចផ្តល់សេវា ដែលគេអាចចាត់ទុកថាជាសេវាអប់រំក្រៅប្រព័ន្ធ ប៉ុន្តែមិនបានចុះបញ្ជិកាជាមួយនឹងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធប៉ុន្តែបានចុះជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឬក្រសួង សង្គមកិច្ចឬក្រសួងកិច្ចការនារីទៅវិញ។

ខាងក្រោមនេះ គឺជាឧទាហរណ៍ ដែលបង្ហាញពីប្រភេទសេវា ដែលអង្គការក្រៅរដ្ឋាភិបាលផ្តល់ ហើយដែលមិនមានភាពច្បាស់លាស់ ថាតើកម្មវិធីទាំងនេះគួរចាត់ទុកថាជាសេវាអប់រំក្រៅប្រព័ន្ធ ឬអត់នោះ។

---

[5] Department of Non-Formal Education (2002), ‘Policy of Non-Formal Education’. MoEYS

**តារាង៥** ៖ សេវាផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល ដែលខ្វះភាពច្បាស់លាស់ពាក់ព័ន្ធជាមួយនឹងការបែងចែក ជាប្រភេទការអប់រំក្រៅប្រព័ន្ធ

| ល.រ. | ឧទាហរណ៍ដែលបង្ហាញពីសេវារបស់អង្គការក្រៅរដ្ឋាភិបាល ដែលខ្វះភាពច្បាស់លាស់ពាក់ព័ន្ធជាមួយនឹងការបែងចែក ជាប្រភេទការអប់រំក្រៅប្រព័ន្ធ |
|---|---|
| ១ | កម្មវិធីបង្កើនចំណូល |
| ២ | ថ្នាក់មត្តេយ្យសហគមន៍ |
| ៣ | កម្មវិធីអប់រំពីរភាសា |
| ៤ | ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រ |
| ៥ | ការបណ្តុះបណ្តាលភាសាអង់គ្លេស |

អង្គការក្រៅរដ្ឋាភិបាលមួយបន្ថែមទៀតអាចថាពេលដែលសេវាអ្វីមួយដែលត្រូវបានចាត់ទុកថាជាសេវាអប់រំក្រៅប្រព័ន្ធ ត្រូវបានចូលរៀនដោយសិស្សសាលា។ បច្ចុប្បន្ននេះនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ឬ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចាត់ទុកថាប្រសិនបើមានករណីបែបនេះ នោះកម្មវិធីនេះមិនគួរចាត់ទុកថាជាកម្មវិធីអប់រំក្រៅប្រព័ន្ធឡើយ ។ កម្មវិធីបង្កើនចំណូលជាច្រើនមានទំនាក់ទំនងជាមួយនឹងកម្មវិធីបំណិនជីវិត ដែលជួយប្រជាពលរដ្ឋក្នុងការបង្កើនចំណូល ដូចជា អ៊ុតសក់ ជាដើមដែលអាចទាក់ទាញសិស្សសាលាផងដែរ។ មិនតែប៉ុណ្ណោះ ដូចដែលនឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ផ្នែកបន្ទាប់មកទៀតថាសិស្សក្នុងប្រព័ន្ធភាគច្រើនបានប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍ជាផ្នែកដ៏សំខាន់មួយនៃកម្មវិធី ។

លើសពីនេះ នៅក្នុងករណីដែលសេវាអប់រំក្រៅប្រព័ន្ធមិនប្រើប្រាស់សៀវភៅសិក្សា ដែលអនុម័តដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នោះនាយកដ្ឋានអប់រំក្រៅប្រព័ន្ធមិនចាត់ទុកកម្មវិធីទាំងនេះថាជាប្រភេទ កម្មវិធីអប់រំក្រៅប្រព័ន្ធនោះទេ។ នេះនាំឱ្យមានផលប៉ះពាល់ជាពិសេសដល់កម្មវិធីជំនាញ មុខរបរ/បំណិនជីវិត និងកម្មវិធីសមមូល។ នេះមានន័យថា មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលកំពុងអនុវត្តកម្មវិធីអប់រំពីរភាសា ដោយប្រើប្រាស់កម្មវិធីសិក្សា និងសៀវភៅសិក្សាផ្ទាល់ខ្លួន ប៉ុន្តែមិនចាត់ទុកខ្លួនឯងថាកំពុងផ្តល់ សេវាអប់រំក្រៅប្រព័ន្ធ។

# កម្មវិធីអក្ខរកម្ម

កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ និងបំណិនជីវិត មានគោលបំណងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាចេះអាន សរសេរ និងរាប់លេខ ហើយផ្តល់ឱ្យពួកគេនូវជំនាញ ដើម្បីជួយដល់ពួកគេ នៅក្នុងជីវិតនិងការអនុវត្តសកម្មភាពប្រចាំថ្ងៃ ។ អង្គការក្រៅរដ្ឋាភិបាល ដែលកំពុងអនុវត្តកម្មវិធីអក្ខរកម្ម រួមមាន ៖

បើតាមគោលនយោបាយរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ កម្មវិធីអក្ខរកម្មមានគោលបំណងផ្តោតគោលដៅលើអ្នកដែលមានអាយុពី 15-45 ឆ្នាំ ហើយតារាងខាងក្រោមបង្ហាញថា មានអ្នកសិក្សា 2626 នាក់ក្នុងចំណោម 4503នាក់ ដែលចុះឈ្មោះចូលរៀនក្នុងកម្មវិធីនេះ មានអាយុចន្លោះ 15និង 45 ឆ្នាំ។ នេះស្មើនឹង 58% នៃចំនួនអ្នកសិក្សាសរុបដែលបានចុះឈ្មោះចូលរៀន ឬ 61% នៃចំនួនអ្នកសិក្សាទាំងអ សដែលគេដឹងពីអាយុ (សរុប 4296 នាក់)។

**តារាងទី៦៖** ចំនួនអ្នកសិក្សាក្នុងកម្មវិធីអក្ខរកម្មតាមក្រុមអាយុ




*

* ចំនួនសរុប គឺច្រើនជាចំនួនក្រុមអាយុទាំងអស់បូកបញ្ចូលគ្នា ដោយសារតែគេមិនដឹងពីអាយុរបស់អ្នកសិក្សាមួយចំនួន

ប៉ុន្តែ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺថា មានជាងមួយភាគបី ( 38%) នៃអ្នកសិក្សាទាំងអស់ដែលបានចុះឈ្មោះចូលរៀន នៅក្នុងកម្មវិធីអក្ខរកម្មហើយដែលគេមិនស្គាល់ពីអាយុរបស់ពួកគេ មានអាយុក្រោម 15ឆ្នាំ ។ នេះបង្ហាញពីតម្រូវការអក្ខរកម្មក្នុងកម្រិតខ្ពស់ របស់កុមារដែលទំនងជាបានបោះបង់ចោលការសិក្សា ឬដែលមិនធ្លាប់ចូលរៀនទាល់តែសោះ។ វិស័យអប់រំក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ គួរធ្វើការប្រាស្រ័យទាក់ទងជាមួយគ្នាដើម្បីរៀបចំផែនការផ្តល់សេវានានាជាពិសេសនៅតាមទីកន្លែងដែលមានចំនួនកុមារបោះបង់ចោលការសិក្សាក្នុងកម្រិតខ្ពស់ហើយលើសពីនេះគួរពិចារណាថាតើមានភាពចាំបាច់ដើម្បីធ្វើការពិនិត្យឡើងវិញលើគោលដៅរបស់កម្មវិធី

អប់រំក្រៅប្រព័ន្ធនៅក្នុងគោលនយោបាយដែរឬទេ ។ មានមនុស្ស អាយុជាង 45ឆ្នាំ តែ 34 នាក់ ប៉ុណ្ណោះ ដែលចុះឈ្មោះសិក្សានៅក្នុងកម្មវិធីអក្ខរកម្ម។

មានការព្រួយបារម្ភមួយ ដោយសារតែមានអ្នកសិក្សា ដែលចុះឈ្មោះសិក្សាក្នុងកម្មវិធីអក្ខរកម្មតែ 39% ប៉ុណ្ណោះ ដែលបានបញ្ចប់កម្មវិធីនេះ។ កម្រងសំណួរ ដែលត្រូវបានប្រើប្រាស់ មិនបានផ្តល់ឱកាសឱ្យ NEP សាកសួរអង្គការក្រៅរដ្ឋាភិបាលនានាអំពីអត្រាបញ្ចប់ការសិក្សារបស់ពួកគេឡើយប៉ុន្តែយើងរំពឹងថាអង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តកម្មវិធីអក្ខរកម្មនឹងធ្វើការស្រាវជ្រាវអំពីមូលហេតុដែលនាំឱ្យការបញ្ចប់ការសិក្សាក្នុងកម្មវិធីអក្ខរកម្មមានកម្រិតទាបបែបនេះ និងធ្វើការពិចារណាលើភាពពាក់ព័ន្ធរបស់កម្មវិធីចំពោះក្រុមអាយុផ្សេងៗគ្នាដែលអាចជាបញ្ហាដំបូង ដែលត្រូវយកមកធ្វើការពិចារណា ដោយសារតែអត្រាបញ្ចប់ការសិក្សា មានការកើនឡើង នៅពេលដែលអាយុរបស់អ្នកចូលរៀនមានការកើនឡើង។ ឧទាហរណ៍៖ អត្រាបញ្ចប់ការ សិក្សារបស់អ្នកដែលមានអាយុក្រោម 15 ឆ្នាំ មានត្រឹមតែ 21% ប៉ុណ្ណោះ កើនឡើងដល់ 51% សម្រាប់អាយុ 15-24ឆ្នាំ, 54% សម្រាប់អាយុ25-45ឆ្នាំ និងកើនឡើងដល់ 85% សម្រាប់អ្នកដែលមាន អាយុជាង 45ឆ្នាំ ។ ប៉ុន្តែគួរមានការចងចាំថាចំនួនមនុស្សដែលមានអាយុជាង 45ឆ្នាំជាក់ស្តែងមានចំនួនតិចតួចបំផុត។

មូលហេតុដែលរួមចំណែកអាចដោយសារតែឯកសារបង្រៀននិងវគ្គសិក្សាមិនមានភាពសមស្របសម្រាប់មនុស្សដែលមានអាយុក្រោម15ឆ្នាំ។ ការមានសៀវភៅសិក្សាអក្ខរកម្មតែមួយសម្រាប់ប្រើប្រាស់ជាមួយនឹងសិស្សគ្រប់អាយុទាំងអស់ អាចមិនមានប្រសិទ្ធភាពឡើយ ហើយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលគួរពិចារណាផលិតឯកសារផ្សេងៗដែលអាចយកទៅប្រើប្រាស់ជាមួយនឹងក្រុមគោលដៅផ្សេងៗគ្នា។

បើធៀបជាមួយនឹងតារាងមុន តារាងនេះដែលបង្ហាញតែពីអ្នកចូលរួមជាស្ត្រីសុទ្ធនេះ បង្ហាញថា ៦៦% នៃអ្នកដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអក្ខរកម្ម គឺជាស្ត្រី។ លទ្ធផលនេះ គឺស្រដៀងគ្នាជាមួយ ភាគរយរបស់ស្ត្រី ដែលចូលរួមក្នុងកម្មវិធីអក្ខរកម្ម ឬបំណិនជីវិតរបស់រដ្ឋាភិបាល។ [6] នៅក្នុងប្រភេទអាយុ 25-45ឆ្នាំ 85% នៃអ្នកដែលបានចុះឈ្មោះចូលរៀនគឺជាស្ត្រីខណៈពេលដែលស្ត្រីដែលមានអាយុក្រោម 15ឆ្នាំមាន 60% នៃអ្នកដែលមានអាយុក្រោម 15ឆ្នាំ ដែលបានចុះឈ្មោះសិក្សា។

[6] Department of NFE, Received at a meeting on 29th January 2013

**តារាងទី ៧ ៖** ចំនួនស្ត្រី នៅក្នុងកម្មវិធីអក្ខរកម្ម




* ចំនួនអ្នកចុះឈ្មោះចូលរៀនសរុប គឺច្រើនជាងក្រុមអាយុសរុបបញ្ចូលគ្នា ដោយសារតែអាយុរបស់អ្នកចូលរួម ក្នុងគ្រប់កម្មវិធីទាំងអស់មិនត្រូវបានគេដឹងឡើយ។

ជាក់ស្តែងអត្រាបញ្ចប់ការសិក្សារបស់ស្ត្រីមានកម្រិតទាបជាកម្រិតនៃការសិក្សាជារួមពោលគឺមានត្រឹមតែ36% ប៉ុណ្ណោះ។ និន្នាការដូចគ្នានេះដែលអត្រាបញ្ចប់ការសិក្សាមានការកើនឡើងនៅពេលដែលអាយុមានការកើនឡើងគឺមានដូចគ្នាសម្រាប់គ្រប់អ្នកសិក្សាទាំងអស់ ដូចគ្នានឹងសម្រាប់អ្នកសិក្សាជាស្ត្រីដែរ។ អ្នកដែលមានអាយុក្រោម 15ឆ្នាំ ចំនួន 22% បានបញ្ចប់ការសិក្សា អ្នកដែលមានអាយុ 15-24ឆ្នាំ 38% បានបញ្ចប់ការសិក្សា ហើយអ្នកដែលមានអាយុ 25-45ឆ្នាំ 53% បានបញ្ចប់ការសិក្សា ហើយស្ត្រីដែលមានអាយុលើសពី 45ឆ្នាំ ខ្ពស់រហូតដល់ 80% បានបញ្ចប់វគ្គសិក្សានេះ។ ចំណុចខុសប្លែកគ្នាមួយជាមួយនឹងបុរស គឺស្ត្រីដែលមានអាយុ 15-24ឆ្នាំ មិនសូវជាទំនងអាចបញ្ចប់វគ្គអក្ខរកម្មឡើយ។

គោលនយោបាយរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក៏បានលើកឡើងផងដែរថា សេវាអក្ខរកម្មអាចធ្វើឡើងនៅតាមទីកន្លែងនានាដូចជានៅតាមភូមិ វត្តអារាម មជ្ឈមណ្ឌលសិក្សាសហគមន៍ កន្លែងធ្វើការឬ បរិវេណអង្គការក្រៅរដ្ឋាភិបាល។ ការស្រាវជ្រាវរបស់យើងបានរកឃើញថា សេវាអក្ខរកម្មរបស់អង្គការ ក្រៅរដ្ឋាភិបាលភាគច្រើន ដែលមានទីតាំងនៅក្នុងផ្ទះរបស់ប្រជាពលរដ្ឋ គឺជាសេវាដែលផ្តល់ញឹកញាប់ជាងគេ។ ទីតាំងទាំងនេះដែលត្រូវបានគេកត់ត្រា ***"ដីទៃទៀត"*** មានទីតាំងភាគច្រើន នៅតាមទីតាំងរបស់អង្គការក្រៅរដ្ឋាភិបាល ឬកន្លែងធ្វើការ។ ដូចដែលបានឃើញកន្លងមក សេវារបស់អង្គការក្រៅរដ្ឋាភិបាលចំនួន 9% មានទីតាំងនៅតាមសាលារៀន ដែលដូចករណីមុនដែរ អាចនាំឱ្យមានការភ័ន្តច្រឡំថាតើថាវាគឺជាសេវាអប់រំ ក្រៅប្រព័ន្ធ ឬអត់។

**តារាងទី ៨ ៖** ទីតាំងសេវាអក្ខរកម្ម




# កម្មវិធីជំនាញមុខរបរ

កម្រងសំណួរដែលត្រូវបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡាមានឱ្យធ្វើការបែងចែករវាងកម្មវិធីអក្ខរកម្ម និងកម្មវិធីជំនាញ មុខរបរ ជាជាងរវាងកម្មវិធីអក្ខរកម្ម និងកម្មវិធីបំណិនជីវិតដូច្នេះព័ត៌មានដែលបង្ហាញនៅទីនេះ គឺជាព័ត៌មានអំពីកម្មវិធីជំនាញមុខរបរ។

កម្មវិធីជំនាញមុខរបរ គឺជាកម្មវិធីដ៏សំខាន់មួយ សម្រាប់ឱ្យអ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ កែលំអជីវភាពរស់នៅរបស់ខ្លួន។ ក្រសួងអប់រំ យុវជន និងកីឡាជឿជាក់ថា កម្មវិធីនេះមានសារៈសំខាន់ យ៉ាងខ្លាំងដែលគ្រប់សកម្មភាពអប់រំក្រៅប្រព័ន្ធទាំងអស់គួរមានដាក់បញ្ចូលការបណ្តុះបណ្តាលអំពីជំនាញមុខរបរនេះ ។ ក្រសួងអប់រំ យុវជន និងកីឡា ក៏ស្នើផងដែរថា បន្ថែមពីលើការបណ្តុះបណ្តាលជំនាញ មុខរបរ អ្នកផ្តល់សេវាអាចពិចារណាផ្តល់ឥណទាន ដើម្បីជួយឱ្យប្រជាពលរដ្ឋអាចចាប់ផ្តើមមុខរបរអាជីវកម្មដោយខ្លួនឯងបាន។ [7]

ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលទាំងនេះ អង្គការគាំពារកុមារខ្មែរ (CYK) អនុវត្តកម្មវិធីច្រើនជាងគេរហូតដល់ 23កម្មវិធីជំនាញ បន្ទាប់មកអង្គការ Friends/មិត្តសំឡាញ់ ដែលមាន កម្មវិធីចំនួន 12 សមាគមន៍អភិវឌ្ឍស្ត្រី (WDA) មាន 9 កម្មវិធី ហើយអង្គការ Khmer New Generation មានកម្មវិធីជំនាញចំនួន 8 ។ អង្គការដ៏ទៃទៀត ដូចជា AFESIP, កុមារនៃក្តីសង្ឃឹម, NIF, CAD, ROO, ជីវិតនៅកម្ពុជា, DDSP និងដំណក់ទឹកអ្នកលឿង (NTC-neakloeurng) ជាដើម សុទ្ធតែមានកម្មវិធីជំនាញក្នុងចំនួនប្រហាក់ប្រហែលគ្នាពី 1 ដល់ 6 ។

[7]Department of Non-Formal Education (2002), 'Policy of Non-Formal Education'- MoEYS

ការងារបណ្តុះបណ្តាលជំនាញមុខរបរអប់រំក្រៅប្រព័ន្ធមានញឹកញាប់ជាងគេគឺ នៅទីកន្លែង ***“ដ៏ទៃទៀត”*** ដែលភាគច្រើន គឺជាទីតាំងរបស់អង្គការក្រៅរដ្ឋាភិបាល។ មានការបណ្តុះបណ្តាលជំនាញ មុខរបរជិតមួយភាគបួនដែលធ្វើឡើងក្នុងសាលារៀន។ នេះអាចដោយសារកង្វះទីតាំងរូបវ័ន្តផ្សេ ងៗទៀត នៅក្នុងសហគមន៍ហើយអាចត្រូវបានគេចាត់ទុកជាការប្រើប្រាស់អគារសិក្សាឱ្យមានប្រយោជន៍ល្អ ។ វាអាចដោយសារតែមានសិស្សសាលាចូលរៀននៅក្នុងការបណ្តុះបណ្តាលជំនាញមុខរបរផងដែរ។

**<u>តារាងទី៩៖</u>** ទីតាំងរបស់កម្មវិធីបណ្តុះបណ្តាលជំនាញមុខរបរ




ព័ត៌មានខាងក្រោមឆ្លុះបញ្ចាំងពីការបង្កើតកម្មវិធីជំនាញមុខរបរនៅតាមតំបន់និងខេត្តនានាដែលមានតម្រូវការ និងក្រុមគោលដៅច្រើន។ ក្រុងភ្នំពេញមានកម្មវិធីជំនាញ មុខរបរច្រើនជាងគេ បន្ទាប់មក គឺ ខេត្តបាត់ដំបង ព្រៃវែង កណ្តាល និងតាកែវ។ ខេត្ត ដែលមានសេវាក្នុងចំនួនតិចជាងគេរួមមាន ខេត្តប៉ៃលិន ព្រះវិហារ និងសៀមរាប។ យើងសង្ស័យថា មានអង្គការក្រៅរដ្ឋាភិបាល ដែលមានដំណើរការ នៅក្នុងខេត្តសៀមរាប ដែលកំពុងផ្តល់សេវាទាំងនេះ ប៉ុន្តែយើងមិនអាចសម្ភាសជាមួយនឹងអង្គការទាំងនេះបានឡើយ។

**ប្រភេទជំនាញមុខរបរ រួមមាន ៖**

- កម្មវិធីបង្កើនប្រាក់ចំណូល
- ការបណ្តុះបណ្តាលកុំព្យូទ័រ
- ការបណ្តុះបណ្តាលភាសាអង់គ្លេស
- ជំនាញកាត់ដេរ
- ជំនាញធ្វើម្ហូប និងនំ/ជំនាញដាំស្ល
- ជំនាញអ៊ុតសក់ និងកែសម្ផស្ស
- សិល្បៈនៃជំនាញដេរប៉ាក់/សូត្រជាប្រពៃណី
- បច្ចេកទេសដាំស្រូវ
- ជំនាញត្បាញកន្ទេល/ជំនាញត្បាញកន្ត្រក់ផ្តៅ
- ការដាំបន្លែ
- ការចិញ្ចឹមសត្វ/ត្រី
- ជួសជុលកង់ និងម៉ូតូ
- អគ្គិសនី/ជួសជុលម៉ាស៊ីនត្រជាក់/ទូរស័ព្ទដៃ និងទូរទឹកកក
- ជួសជុលឡាន
- សិល្បៈគូររូប
- ជំនាញជាងឈើ និងសង្ហារឹម
- ជំនាញសូនរូប និងឆ្លាក់រូប/ឆ្លាក់លោហធាតុ
- ជំនាញនិទានរឿង
- ជំនាញបោះពុម្ពលើអាវយឺត
- ជំនាញភ្លេង និងរបាំបុរាណ

មានអ្នកចូលរួមសរុបចំនួន2815នាក់ដែលបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីជំនាញមុខរបររបស់អង្គការ ក្រៅរដ្ឋាភិបាលនៅក្នុងឆ្នាំ 2012ខណៈពេលដែល 2217នាក់ បានបញ្ចប់វគ្គសិក្សារបស់ពួកគេ។ ក្នុងចំណោមអ្នកដែលបានចុះឈ្មោះ និងបញ្ចប់ការសិក្សា យើងមានព័ត៌មានលំអិតអំពីអាយុសម្រាប់អ្នកចុះឈ្មោះចំនួន 2367នាក់ និងអ្នកបញ្ចប់ការសិក្សាតែ 1606នាក់តែប៉ុណ្ណោះ។ ក្រុមអាយុគោលដៅសម្រាប់កម្មវិធីនេះ គឺ 15-45ឆ្នាំ ហើយអ្នកដែលបានចុះឈ្មោះ 85% និងអ្នកដែលបានបញ្ចប់ការសិក្សា 83% ស្ថិតនៅក្នុងក្រុមអាយុគោលដៅនេះ។

**តារាងទី ១០** ៖ ចំនួនអ្នកចូលរួមក្នុងកម្មវិធីជំនាញមុខរបរតាមអាយុ




ប៉ុន្តែ អ្នកដែលមានអាយុក្រោម 15ឆ្នាំ មានប្រមាណជា 14% នៃអ្នកដែលបានចុះឈ្មោះ និង 17% នៃអ្នកដែលបានបញ្ចប់ការសិក្សាតែប៉ុណ្ណោះ ។ នេះគឺជាចំនួនមួយដ៏ច្រើន ជាពិសេស ដោយសារតែ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិទទួលបានការអប់រំកម្រិតមូលដ្ឋាន រហូតដល់ថ្នាក់ទី 9 ដែលសមមូលនឹងអាយុ 15ឆ្នាំ ហើយក៏អាចទទួលបានការបណ្តុះបណ្តាលជំនាញមុខរបរនៅសាលារៀនផងដែរ ។ ប៉ុន្តែនៅក្នុងកំឡុងពេលធ្វើការស្រាវជ្រាវរបស់យើងនេះអង្គការក្រៅរដ្ឋាភិបាលបានលើកឡើងថា ជួនកាលកុមារដែលចូលរៀននៅក្នុងការបណ្តុះបណ្តាលជំនាញមុខរបរនេះ ក៏នៅតែអាចទៅរៀនក្នុងសាលាដូចធម្មតាដែរ។ ដូចករណីមុនដែរនេះគឺជាករណីលំបាកក្នុងការកំណត់ពីសេវាអប់រំក្រៅប្រព័ន្ធ តែតាមរយៈថាតើអ្នកចូលរៀនកំពុងរៀននៅក្នុងសាលា ឬបានបាត់បង់ចោលការសិក្សា។

បើទោះបីជាយើងមានព័ត៌មានលំអិតអំពីស្ត្រីទាំង 1638នាក់ ដែលបានបញ្ចប់កម្មវិធីបំណិនជីវិត ឬជំនាញមុខរបរក៏ដោយ យើងមានព័ត៌មានលំអិតអំពីអាយុតែរបស់ស្ត្រីចំនួន 1026នាក់តែប៉ុណ្ណោះ។ ដូច្នេះក្នុងចំណោមស្ត្រីទាំង 1026នាក់នេះ មាន 20% អាយុក្រោម 15ឆ្នាំ មានន័យថា ស្ត្រីមានភាគច្រើនខ្ពស់ជាង ក្នុងចំណោមអ្នកចូលរៀនអាយុក្រោម 15ឆ្នាំ ដែលចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញ មុខរបរ បើធៀបជាមួយនឹងបុរស។ ក្រុមអាយុគោលដៅ 15-45ឆ្នាំ មានចំនួនស្មើរនឹង 67% នៃអ្នកដែលបានចុះឈ្មោះ និង អ្នកដែលបានបញ្ចប់ការសិក្សា។

**តារាងទី ១១** ៖ ចំនួនស្ត្រីនៅក្នុងកម្មវិធីជំនាញមុខរបរ




## កម្មវិធីចូលរៀនឡើងវិញ

កម្មវិធីចូលរៀនឡើងវិញ គឺជាកម្មវិធីខ្លី ដែលមានរយៈពេល 8សប្តាហ៍ ដែលត្រូវបានរៀបចំឡើងនៅក្នុងវិស្សមកាល ដើម្បីផ្តល់លទ្ធភាពឱ្យសិស្សដែលបានបោះបង់ចោលការសិក្សា អាចវិលត្រឡប់ចូលរៀនក្នុងសាលាវិញនៅពេលដែលសាលាចូលរៀនឡើងវិញនៅក្នុងខែតុលា ។ កម្មវិធីនេះគួរមានគោលបំណងផ្តោត ក្រុមគោលដៅកុមារដែលបោះបង់ចោលការសិក្សាពិតប្រាកដដែលមានបំណងចូលរៀនក្នុងសាលាសារជាថ្មី ។ អង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់កម្មវិធីចូលរៀនឡើងវិញ មានថ្នាក់សម្រាប់ពីថ្នាក់ទី 1ដល់ទី 6។

**តារាងទី ១២** ៖ ចំនួនអ្នកចូលរៀនក្នុងកម្មវិធីចូលរៀនឡើងវិញ



ផ្អែកទៅតាមក្រាហ្វខាងលើ យើងអាចមើលឃើញថា មានសិស្ស 100% ដែលបានចុះឈ្មោះចូលរៀនបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញរបស់ពួកគេ ហើយមានសិស្សទាំង 468នាក់ លើកលែងតែ 2នាក់ចេញដែលឡើងទៅរៀននៅថ្នាក់បន្ទាប់។ ប៉ុន្តែ មានការព្រួយបារម្ភមួយ ដោយសារតែកម្មវិធីចូលរៀន ឡើងវិញមិនគាំទ្រដល់សិស្សដែលបានបោះបង់ចោលការសិក្សាប៉ុន្តែគាំទ្រដល់សិស្សដែលមិនបានប្រឡងជាប់ចុងឆ្នាំទៅវិញ។ កុមារដែលមិនបានប្រឡងចុងឆ្នាំជាប់អាចចូលរៀនវគ្គសិក្សាចូលរៀនឡើងវិញរយៈពេល2ខែនៅក្នុងវិស្សមកាលរបស់សាលារៀននៅខែសីហានិងកញ្ញា មុនពេលដែលពួកគេអាចប្រឡងសារជាថ្មីដើម្បីឡើងទៅរៀននៅថ្នាក់បន្ទាប់ ។ មានកុមារទាំងអស់ដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីចូលរៀនឡើងវិញបានបញ្ចប់ការសិក្សាក្នុងកម្មវិធីនេះមួយរយភាគរយ ព្រមទាំងលើកលែងតែកុមារ 2នាក់ចេញ ត្រូវបានឡើងទៅរៀននៅថ្នាក់បន្ទាប់ នេះគឺជាការបង្ហាញឱ្យឃើញថាកម្មវិធីចូលរៀនឡើងវិញកំពុងគាំទ្រដល់កុមារប្រភេទនេះមិនមែនលើកុមារដែលនៅក្រៅសាលាទាំងស្រុងនោះទេ។ វាមិនទំនង ថា កុមារ 100% ដែលធ្លាប់បោះបង់ចោលការសិក្សាកន្លងមក សុទ្ធតែបញ្ចប់កម្មវិធីចូលរៀនឡើងវិញ ហើយត្រៀមឡើងទៅរៀននៅថ្នាក់បន្ទាប់ឡើយ។

រដ្ឋាភិបាលគួរបង្កើតគោលការណ៍ណែនាំ ដើម្បីឱ្យកម្មវិធីចូលរៀនឡើងវិញអាចកត់ត្រាថាតើមានសិស្សប៉ុន្មាននាក់ ដែលចូលរួម គឺជាសិស្សដែលបានបោះបង់ចោលការសិក្សា។ នេះតម្រូវឱ្យសាលារៀនរក្សាឯកសារឱ្យបានសុក្រឹតអំពីចំនួនកុមារដែលបានបោះបង់ចោលការសិក្សា ដែលយើងខ្លាចថា មិនមានការធ្វើ បែបនេះនាពេលបច្ចុប្បន្ននេះ។ តាមពិតទៅហាក់បីដូចជាមិនមាននិយមន័យដែលត្រូវបានគេប្រើជាសកលអំពីសិស្សបោះបង់ចោលការសិក្សា និងសិស្សក្រៅសាលារៀននោះឡើយ។ សាលារៀនមួយចំនួនកត់ត្រាថា មានកុមារម្នាក់បានបោះបង់ចោលការសិក្សា ប្រសិនបើកុមារម្នាក់នោះមិនមករៀនលើសពី 1ខែពេលខ្លះជាងមួយឆមាសនិងជួនកាលកុមារអាចត្រូវបានគេកត់ត្រាថាបានបោះបង់ចោលការសិក្សា ប្រសិនបើតាមពិតគេបានទៅរៀននៅសាលាមួយទៀត។

## កម្មវិធីសមមូល

កម្មវិធីទាំងអស់ លើកលែងតែកម្មវិធីមួយចេញ ដែលកំពុងត្រូវបានអនុវត្តដោយអង្គការក្រៅ រដ្ឋាភិបាលកំពុងស្ថិតនៅក្នុងទីតាំងរបស់អង្គការក្រៅរដ្ឋាភិបាលតែម្តង ហើយកម្មវិធីដ៏ទៃទៀតមានទីតាំង ស្ថិតនៅក្នុងផ្ទះរបស់បុគ្គល។ ពុំមានកម្មវិធីណា ដែលមានទីតាំងនៅទីកន្លែងនានា ដូចជា វត្តអារាម មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬសាលារៀននោះទេ។ មានកម្មវិធីសមមូលស្ទើរតែទាំងអស់ក្នុងចំណោម កម្មវិធីសមមូលទាំង ២៨ ពោលគឺមាន ២៦ កម្មវិធី ដែលផ្តោតគោលដៅលើថ្នាក់បឋមសិក្សា។

កម្មវិធីសមមូលទាំងនេះមានគោលបំណងផ្តល់លទ្ធភាពឱ្យសិស្សក្រៅសាលា អាចបញ្ចប់កម្មវិធីមួយដោយទទួលបានការអប់រំបំណិនជីវិតមួយចំនួន និងប្រឡងជាប់ ដែលអាចឱ្យពួកគេអាចចូលរៀនឡើងវិញ នៅថ្នាក់សមស្រប។ នាពេលបច្ចុប្បន្ននេះ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធមានត្រឹមតែកម្មវិធីសិក្សា ដែលបង្កើត ឡើង

សម្រាប់ថ្នាក់ទី3 ដល់ទី 6 តែប៉ុណ្ណោះ ហើយនៅពេលដែលកុមារបានប្រឡងជាប់ កុមារនេះអាចចូលរៀនថ្នាក់ទី7បាន។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធបានរៀបចំសេចក្តីព្រាងកម្មវិធីសិក្សា និងសៀវភៅសិក្សាសម្រាប់ថ្នាក់មធ្យមសិក្សាបឋមភូមិដែរ ប៉ុន្តែនៅមិនទាន់បានបញ្ចប់នៅឡើយ។

ក្នុងចំណោមសិស្សចំនួន 403នាក់ ដែលបានចុះឈ្មោះសម្រាប់ប្រឡងនៅឆ្នាំទី 2 របស់កម្មវិធីសិក្សាសមមូលមាន364នាក់បានប្រឡងជាប់(90%)។ស្ត្រីមានចំនួនស្មើពាក់កណ្តាលនៃបេក្ខជនសរុបដែលបានប្រឡងជាប់ឆ្នាំទី២ និងមានច្រើនជាងពាក់កណ្តាលតិចតួចនៃចំនួនបេក្ខជន ដែលចូលរួមក្នុងការប្រឡងនេះ។

ទៅតាមអ្វីដែលរំពឹងទុកជាមុន សិស្សភាគច្រើនមានអាយុក្រោម 15ឆ្នាំ ប៉ុន្តែមានសិស្ស 323នាក់នៅចុងឆ្នាំដែលមានអាយុ15-24ឆ្នាំស្មើនឹង 37% នៃសិស្សនៅចុងឆ្នាំទាំងអស់។ នេះបង្ហាញថាវគ្គសិក្សានេះមិនត្រឹមតែផ្តល់សេវាដល់អ្នកដែលចង់វិលត្រឡប់មកចូលរៀនក្នុងសាលាធម្មតាប៉ុណ្ណោះទេប៉ុន្តែមនុស្សជាច្រើននាក់ដែលមិនធ្លាប់រៀនចប់សាលាបឋមសិក្សាហើយចង់ទទួលបានការអប់រំកម្រិតមូលដ្ឋានដោយអាចទទួលបានបំណិនជិវិត មួយចំនួនផងដែរ។

**តារាងទី ១៣** ៖ ចំនួនអ្នកចូលរៀនក្នុងកម្មវិធីសមមូល បែងចែកតាមក្រុមអាយុ




ស្ត្រីច្រើនតែទំនងជានឹងបោះបង់ចោលការសិក្សា ក្នុងកម្មវិធីនេះ មុនដល់ចុងឆ្នាំ ដោយសារតែមាន ស្ត្រីត្រឹមតែ 42.5% ប៉ុណ្ណោះនៃចំនួនសរុបនៅចុងឆ្នាំ ប៉ុន្តែមាន 56% នៅដើមឆ្នាំ។ ប៉ុន្តែ ទោះជាយ៉ាងណា ក៏ដោយមានការរាយការណ៍ថា មានមនុស្សមួយចំនួនចូលរៀនក្នុងកម្មវិធីសមមូលនៅក្នុងឆ្នាំដែលបង្ហាញដោយសារមានមនុស្សអាយុ 15-24ឆ្នាំមាន323នៅចុងឆ្នាំ ប៉ុន្តែមានត្រឹមតែ 207នាក់ នៅដើមឆ្នាំ។ នេះមាន ផលប៉ះពាល់លើអត្រាបញ្ចប់ការសិក្សា បើធៀបចំនួននៅចុងឆ្នាំ ជាមួយនឹងចំនួននៅដើមឆ្នាំ។

**តារាងទី ១៤** ៖ ចំនួនអ្នកចូលរៀនក្នុងកម្មវិធីសមមូលបែងចែកទៅតាមយេនឌ័រ




កម្រងសំណួរអំពីកម្មវិធីសមមូលរបស់ NFE-MIS មិនបានឱកាសឱ្យមានការកត់ត្រាទិន្នន័យ ថាតើអ្នកចូលរៀនរៀននៅកម្រិតមូលដ្ឋាន មធ្យម ឬស្វ័យសិក្សានោះទេ។ ជាអាចជាគំនិតល្អមួយ ប្រសិនបើគេ អាចប្រមូលទិន្នន័យនេះបាននាពេលអនាគត។

## កម្មវិធីបំពេញវិជ្ជា

កម្មវិធីបំពេញវិជ្ជា មានគោលបំណងផ្តល់ឱកាសដល់មនុស្សពេញវ័យ ដែលកន្លងមក មិនធ្លាប់មានឱកាសរៀនចប់ថ្នាក់ទី 12។ កម្មវិធីនេះផ្តល់លទ្ធភាពឱ្យអ្នកចូលរួមបញ្ចប់កម្មវិធីនេះ ហើយទទួលបានជោគជ័យក្នុងការប្រឡងថ្នាក់ទី12ដូចគ្នានឹងការប្រឡង ដែលសិស្សថ្នាក់ទី 12ក្នុងប្រព័ន្ធត្រូវប្រឡងឱ្យ ជាប់ដែរ ។ សៀវភៅសិក្សារបស់កម្មវិធីបំពេញវិជ្ជាក៏ដូចគ្នាទៅនឹងសៀវភៅសិក្សាដែលត្រូវបានប្រើប្រាស់ក្នុងសាលារៀនក្នុងប្រព័ន្ធដែរ បើទោះបីជាការបង្រៀនផ្តោតសំខាន់តែលើមុខវិជ្ជាសំខាន់ៗ ដូចជា ភាសាខ្មែរ គណិតវិទ្យា គីមីវិទ្យា និងរូបវិទ្យាក៏ដោយ។ កម្មវិធីបំពេញវិជ្ជារបស់រដ្ឋាភិបាលច្រើនតែធ្វើឡើងនៅពេល យប់ និងចុងសប្តាហ៍ហើយជាធម្មតាចូលរៀនដោយមនុស្សពេញវ័យ ដែលធ្វើការងារនៅក្នុងវិស័យ សាធារណៈ ឬវិស័យឯកជន។

មានអង្គការក្រៅរដ្ឋាភិបាលតែមួយប៉ុណ្ណោះ ដែលត្រូវបានរកឃើញថាកំពុងអនុវត្តកម្មវិធីបំពេញវិជ្ជានោះគឺអង្គការដុនបូស្កូ។ គ្រប់អ្នកចូលរៀននៅក្នុងកម្មវិធីបំពេញវិជ្ជារបស់អង្គការនេះ មានអាយុចន្លោះពី 15ដល់24ឆ្នាំ។ នេះគឺផ្ទុយគ្នាទៅនឹងអ្វីដែលតែងមាននៅក្នុងកម្មវិធីបំពេញវិជ្ជារបស់រដ្ឋាភិបាល ដែលអ្នកចូលរៀនមានអាយុលើសពី 24ឆ្នាំ។ អាយុពិតប្រាកដរបស់អ្នកចូលរៀន នៅក្នុងកម្មវិធីនេះមិនត្រូវបានប្រមូលឡើយ

ដូច្នេះ យើងមិនដឹងថាតើមានអ្នកចូលរៀនណាខ្លះ ដែលមានអាយុស្របពេលសិក្សា (15-17) នោះឡើយ។ ប្រសិនបើមានអ្នកដែលមានអាយុស្របពេលសិក្សាចូលរៀនក្នុងកម្មវិធីបំពេញវិជ្ជាអាចថាមានសមាសភាគរបស់កម្មវិធីបំពេញវិជ្ជារបស់សាលាដុនបូស្កូដែលទាក់ទាញមនុស្សឱ្យចូលរៀនជាងប្រព័ន្ធអប់រំក្នុងប្រព័ន្ធ ឧទាហរណ៍: ការមិនមានការបង់ថ្លៃសាលាក្រៅផ្លូវការ ហើយគ្រូតែងមានវត្តមានទៀងទាត់ ជាដើម។

**តារាង ១៥៖** ចំនួនសិស្ស នៅក្នុងកម្មវិធីបំពេញវិជ្ជា




អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា មិនមែនគ្រប់សិស្សទាំងអស់ ដែលបញ្ចប់កម្មវិធីបំពេញវិជ្ជា សុទ្ធតែបានចុះឈ្មោះប្រឡងនោះទេ។ នេះអាចដោយសារតែសិស្សមួយចំនួនមិនមានទំនុកចិត្តក្នុងការប្រឡង ហើយសម្រេចចិត្តប្រឡងម្តងទៀត នៅឆ្នាំក្រោយ ឬដោយសារតែមានការធ្វើចំណាកស្រុកមួយចំនួន ក្រោយចុងឆ្នាំ និងមុនពេលប្រឡង។ នេះមានន័យថា មានមនុស្សដែលចាប់ផ្តើមរៀនពីដើមឆ្នាំទៅត្រឹមតែ 26% ប៉ុណ្ណោះដែលប្រឡងថ្នាក់ទី12 ជាប់។

## មជ្ឈមណ្ឌលសិក្សាសហគមន៍

យូណេស្កូបានផ្តល់និយមន័យដល់មជ្ឈមណ្ឌលសិក្សាសហគមន៍ (ម.ស.ស) ដូចខាងក្រោម ៖

*“មជ្ឈមណ្ឌលសិក្សាសហគមន៍ គឺជាកន្លែងផ្តល់ការសិក្សានៅក្នុងមូលដ្ឋាន ខាងក្រៅប្រព័ន្ធអប់រំក្នុងប្រព័ន្ធ។ អាចមានទីតាំងនៅក្នុងភូមិផង និងនៅក្នុងតំបន់ផ្សេងទៀតផង ជាធម្មតា មជ្ឈមណ្ឌលសិក្សា សហគមន៍ត្រូវបានបង្កើតឡើង និងគ្រប់គ្រង ដោយប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីផ្តល់ឱកាសសិក្សារៀន សូត្រ ដើម្បីឱ្យមានការអភិវឌ្ឍសហគមន៍ និងការលើកកម្ពស់គុណភាពជីវិត។ មជ្ឈមណ្ឌលសិក្សាសហគមន៍ មិនចាំបាច់មាន*

*ហេដ្ឋារចនាសម្ព័ន្ធថ្មីនោះទេ ប៉ុន្តែអាចដំណើរការពីមណ្ឌលសុខភាពដែលមានស្រាប់ ព្រះ -វិហារ សាលាបឋមសិក្សា ឬទីកន្លែងសមស្របដទៃទៀត។ មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានទទួល ស្គាល់ថាជាយន្តការផ្តល់សេវាអក្ខរកម្ម និងកម្មវិធីអប់រំបន្តប្រកបដោយប្រសិទ្ធភាព តាមរយៈការប្រើប្រាស់គោលវិធីនៅក្នុងសហគមន៍”* [8]

នៅក្នុងប្រទេសកម្ពុជា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន 302 កន្លែង ដែលក្នុងនោះ 276កន្លែងមានដំណើរការ[9] ហើយមានអង្គការក្រៅរដ្ឋាភិបាលចំនួន 19 ដែលដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍សរុបចំនួន 23 ។

ខេត្តដែលមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងនេះស្ថិតនៅ រួមមាន ៖ ខេត្តបាត់ដំបង កំពង់ចាម ភ្នំពេញ ព្រះសីហនុ សៀមរាប ស្វាយរៀង និងតាកែវ។

ការស្រាវជ្រាវរបស់យើងបានរកឃើញថា សហគមន៍បានប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍សម្រាប់មុខងារច្រើនយ៉ាង ដូចជា ការបណ្តុះបណ្តាលអំពីបញ្ហាសុខភាព ដូចជា មេរោគ/ជំងឺអេដស៍ ការបណ្តុះបណ្តាលបំណិនជីវិត កុំព្យូទ័រនិងការប្រើប្រាស់អ៊ីនធឺណិត វេទិកាជជែកអំពីបញ្ហាឧស្ម័ននិងប្រេង កិច្ចប្រជុំរបស់មាតាបិតា/សហគមន៍ និងការប្រារព្ធពិធីសាធារណៈ/សហគមន៍។ មុខងារនានា ដែលមាននៅតាមទីកន្លែងទាំងនេះ ត្រូវបានរៀបរាប់លំអិតខាងក្រោម រួមជាមួយនឹងភាពញឹកញាប់នៃការបំពេញមុខងារទាំង នេះ។

វាអាចជាការភ្ញាក់ផ្អើលមួយ ដោយសារតែពុំមានមជ្ឈមណ្ឌលសិក្សាសហគមន៍ណាមានវិទ្យុប្រើ ប្រាស់ឡើយ ប៉ុន្តែមានមជ្ឈមណ្ឌលសិក្សាសហគមន៍ 19% ដែលមានទូរទស្សន៍។ ប៉ុន្តែ ផ្ទះភាគច្រើនមាន វិទ្យុប្រើប្រាស់ ហើយមានផ្ទះតិចតួចដែលមានទូរទស្សន៍ ដែលជាការល្អ ដែលមជ្ឈមណ្ឌលសិក្សាសហគមន៍ មានបំពាក់ទូរទស្សន៍ ដែលសមាជិកសហគមន៍អាចប្រើប្រាស់បាន។ ដូចគ្នាដែរ ជាការល្អប្រសើរដែល មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន31% មានកុំព្យូទ័រប្រើប្រាស់ដោយសារតែមានសាលារៀនតែ 381ប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជាដែលមានបរិក្ខារ ICT សម្រាប់ប្រើប្រាស់ ។ [10] ការបង្កើនលទ្ធភាពប្រើប្រាស់ កុំព្យូទ័រ និងជំនាញប្រើប្រាស់កុំព្យូទ័រ មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍសង្គមកម្ពុជា ហើយ មនុស្សគ្រប់វ័យទាំងអស់អាចទទួលបានប្រយោជន៍ពីការរៀនប្រើប្រាស់ឧបករណ៍ទាំងនេះ។

---

[8] Haddad (2007) ‘Strengthening Community Learning Centres through Linkages and Networks’. Bangkok: UNESCO Bangkok

[9] Handout at meeting with DFNE, 29/01/13

[10] Department of NFE, EMIS 2011/12

**តារាងទី ១៦** ៖ ចំនួនសម្ភាររូបវ័ន្តម.ស.ស ដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល




ក្នុងចំណោមមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំង 23 ដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល មានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន17ដែលមានបណ្ណាល័យ ឬបន្ទប់អាន។ មជ្ឈមណ្ឌលសិក្សា សហគមន៍ទាំងអស់នេះមានសៀវភៅបង្រៀន និងរៀន ទស្សនាវដ្តី/កាសែត និងសៀវភៅប្រឡោមលោក/ សៀវភៅរឿង។ មជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់លើកលែងតែ2ចេញ មានផ្តល់នូវសៀវភៅ សាសនា ហើយមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន 12 បានលើកឡើងថា ពួកគេមានឯកសារប្រភេទផ្សេង ទៀត ដែលមិនចូលទៅក្នុងប្រភេទណាមួយ ក្នុងចំណោមប្រភេទទាំងនេះ។

នៅពេលដែលសៀវភៅ ឬទស្សនាវដ្តីណាមួយ ត្រូវបានផ្តល់ទៅឱ្យភ្ញៀវដែលចូលអាន ដើម្បីអាន នៅកន្លែងនោះ ឬដើម្បីយកទៅផ្ទះ ព័ត៍មានលំអិតមួយចំនួនរបស់បុគ្គលនោះត្រូវបានកត់ត្រាទុក។ រូបភាពខាងក្រោម បង្ហាញពីចំនួនកត់ត្រាសរុប ដែលត្រូវបានធ្វើឡើង ហើយដែលយើងគណនារកចំនួនអ្នកអានសរុប បើទោះបីជាមនុស្សដដែលអាចត្រូវបានកត់លើសពីមួយដងក៏ដោយ។

ការស្រាវជ្រាវរបស់យើងបានរកឃើញថា សម្ភាររូបវ័ន្តភាគច្រើន ដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល កំពុងត្រូវបានប្រើប្រាស់ដោយប្រភេទទាំង ៤ របស់អ្នកចូលទស្សនា/អ្នកប្រើប្រាស់/អ្នកអាន ដូចដែលបង្ហាញនៅក្នុងកម្រងសំណួររបស់ NFE-MIS ៖ អ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ សិស្សសាលា គ្រូ

ប្រជាពលរដ្ឋទូទៅ។ នេះបង្ហាញថា សម្ភារប្របរ័ន្ត ដែលត្រូវបានគេចាត់ទុកថាមានសម្រាប់សេវាអប់រំក្រៅ ប្រព័ន្ធ ក៏កំពុងផ្តល់សេវាដល់អ្នកដែលអាចចូលរួម នៅក្នុងការអប់រំក្នុងប្រព័ន្ធផងដែរ។

**តារាង១៧ ៖** ចំនួនអ្នកអាន នៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍




ក្រាហ្វនេះបង្ហាញឱ្យឃើញ ពីបញ្ហានៃការព្យាយាមកំណត់និយមន័យអំពីសេវាអប់រំក្រៅប្រព័ន្ធ។ មជ្ឈមណ្ឌលសិក្សាសហគមន៍មួយ ត្រូវបានចាត់ទុកថាជាសេវាអប់រំក្រៅប្រព័ន្ធ ប៉ុន្តែ ដូចដែលបានឃើញខាងលើ មនុស្ស80%ក្នុងចំណោមអ្នកអានទាំងអស់នៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលដំណើរការដោយ អង្គការក្រៅរដ្ឋាភិបាល គឺជាសិស្សសាលា។ មានមនុស្សសរុប 4301 នាក់ ដែលបានប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍ទាំង23មានន័យថា ជាមធ្យមមានអ្នកអានចំនួន 187 នាក់ ក្នុងមួយមជ្ឈមណ្ឌលសិក្សាសហគមន៍។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធបានរាយការណ៍ថា មានមនុស្ស 7702 នាក់ ដែលបានប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍ទាំង 276 របស់ខ្លួន គិតជាមធ្យមមាន 28 នាក់ ក្នុងមួយមជ្ឈមណ្ឌលសិក្សាសហគមន៍។ បន្ថែមពីលើចំនួនអ្នកអាននៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមិនត្រូវបានបង្ហាញនៅក្នុងរបាយការណ៍គឺជាអ្នកដែលបានចូលរួមក្នុងសកម្មភាពប្រជុំ និង កម្មវិធីផ្សេងៗទៀត ដោយប្រើប្រាស់របស់ធនធានសម្ភារៈនៅក្នុង ម.ស.ស ។

## បណ្ណាល័យ

កម្រងសំណួររបស់ NFE-MIS ពាក់ព័ន្ធនឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ស្នើឱ្យអង្គការក្រៅរដ្ឋាភិបាលផ្តល់នូវព័ត៌មានលំអិត ថាតើពួកគេបង្កើតជាបណ្ណាល័យ ឬមជ្ឈមណ្ឌលសិក្សាសហគមន៍។ មាន

អង្គការក្រៅរដ្ឋាភិបាលចំនួន 9 ដែលផ្តល់នូវបណ្ណាល័យចំនួន 22 ជាអាទិ៍ ៖ អង្គការគាំពារកុមារខ្មែរ ; មូលនិធិកុមារ; FDCC; KADO; មូលនិធិ ប៉ាង; សាលារៀនកម្ពុជា; Welt-Hunger Hilfe (WHH/GAA); YRDP; ដំណាក់ទឹកអ្នកលឿង (NTC-neakloeurng)។

បណ្ណាល័យទាំងនេះមានទីតាំង នៅក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តរតនគិរី ខេត្តព្រៃវែង ខេត្តសៀមរាប និងខេត្តស្វាយរៀង។

ទៅតាមការរំពឹងទុក គ្រប់បណ្ណាល័យទាំងអស់មានធ្នើរសៀវភៅមួយ ប៉ុន្តែសម្ភាររូបវ័ន្តមានច្រើន ជាងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដូចដែលបង្ហាញលំអិតនៅក្នុងតារាងមុននេះ ដោយបណ្ណាល័យមួយចំនួន ថែមទាំងមានវិទ្យុ ទូរទស្សន៍ និងកុំព្យូទ័រថែមទៀតផង។

**តារាង១៨ ៖** ចំនួនសម្ភាររូបវ័ន្តបណ្ណាល័យ ដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល




នៅពេលដែលសៀវភៅ ឬទស្សនាវដ្តីណាមួយ ត្រូវបានផ្តល់ទៅឱ្យភ្ញៀវដែលចូលអាន ដើម្បីអាន នៅកន្លែងនោះ ឬដើម្បីយកទៅផ្ទះ ព័ត៌មានលំអិតមួយចំនួនរបស់បុគ្គលនោះត្រូវបានកត់ត្រាទុក។ រូបភាពខាងក្រោម បង្ហាញពីចំនួនកត់ត្រាសរុប ដែលត្រូវបានធ្វើឡើង ហើយដែលយើងគណនារកចំនួនអ្នកអានសរុប បើទោះបីជាមនុស្សដដែលអាចត្រូវបានកត់លើសពីមួយដងក៏ដោយ។

**តារាង១៩** ៖ អ្នកអានក្នុងបណ្ណាល័យ




គួរកត់សម្គាល់ថា អង្គការម្លប់តាប៉ាង ដែលជាអង្គការមួយក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលធំជាងគេ បានរាយការណ៍ថា មានអ្នកចូលអានជាង 10000នាក់ នៅក្នុងឆ្នាំ 2012ដែលស្មើនឹងបីភាគបួននៃចំនួនមនុស្សសរុបដែលប្រើប្រាស់បណ្ណាល័យ។ អង្គការនេះមានបណ្ណាល័យចល័ត ដែលចុះទៅតាមផ្នែកជា ច្រើនក្នុងខេត្តព្រះសីហនុ ហើយសិស្សដែលរៀនក្នុងកម្មវិធីសមមូល ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ បណ្ណាល័យ ហើយជារឿយៗ ពួកគេពិតជាបានប្រើប្រាស់បណ្ណាល័យមែន។ ដូចគ្នានឹងមជ្ឈមណ្ឌលសិក្សា សហគមន៍ដែរ មានការបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា បណ្ណាល័យច្រើនប្រើដោយសិស្សសាលា ជាងសិស្ស ក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ។

អ្វីដែលជាការព្រួយបារម្ភនោះ គឺថាប្រជាពលរដ្ឋទូទៅ មានភាគរយតិចតួចតែប៉ុណ្ណោះ ពោលគឺត្រឹម តែ ៥% នៃចំនួនមនុស្សសរុប ដែលប្រើប្រាស់បណ្ណាល័យទាំងនេះ ស្រដៀងគ្នាជាមួយនឹងភាគរយនៃអ្នកប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍ និងបន្ទប់អានដែរ។ នេះអាចកើតឡើង ដោយសារកង្វះឯកសារ ដែលសមស្របទៅនឹងមនុស្សពេញវ័យ និងដោយសារការផ្តោតតែលើមនុស្សវ័យក្មេងច្រើនពេក។

តួលេខរបស់រដ្ឋាភិបាលបង្ហាញថា សម្រាប់ឆ្នាំ 2012មានបណ្ណាល័យរដ្ឋដែលមានដំណើរការចំនួន 19 ដែលមានអ្នកចូលអានសរុប 15258នាក់ មានន័យថាបណ្ណាល័យនីមួយៗមានអ្នកអានជាមធ្យម803 នាក់។ នេះ បើធៀបជាមួយនឹងអ្នកអានជាមធ្យម612នាក់ក្នុងមួយបណ្ណាល័យដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាលមួយ។

# បន្ទប់អាន

កម្រងសំណួររបស់ NFE-MIS ពាក់ព័ន្ធនឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ស្នើឱ្យអង្គការក្រៅរដ្ឋាភិបាលផ្តល់នូវព័ត៌មានលំអិត ថាតើពួកគេបង្កើតជាបន្ទប់អាន ឬមជ្ឈមណ្ឌលសិក្សាសហគមន៍។ មានអង្គការក្រៅរដ្ឋាភិបាលចំនួន 3 ដែលបង្កើតនូវបន្ទប់អានចំនួន 7៖ CAD មិត្តសម្លាញ់ និង YRDP។ បន្ទប់ អានទាំងនេះមានទីតាំង នៅក្នុងខេត្តបាត់ដំបង និងភ្នំពេញ។

ដូចអ្វីដែលបានរំពឹងទុកដែរ គ្រប់បន្ទប់អានទាំងអស់មានធ្នើរដាក់សៀវភៅមួយ ប៉ុន្តែគ្រប់បន្ទប់អានទាំងអស់មានទូរទស្សន៍មួយគ្រឿង ហើយមានបន្ទប់អានជាងពាក់កណ្តាល ដែលត្រូវបានប្រើប្រាស់ជាបន្ទប់រៀន។ បើគេពិនិត្យទៅលើសម្ភាររូបវ័ន្តដែលមាន គេពិបាកកំណត់ថាតើទីកន្លែងនេះជាមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ ឬបន្ទប់អានណាស់។

**តារាង ២០៖** សម្ភាររូបវ័ន្ត នៅក្នុងបន្ទប់អាន




នៅពេលដែលសៀវភៅ ឬទស្សនាវដ្តីណាមួយ ត្រូវបានផ្តល់ទៅឱ្យភ្ញៀវដែលចូលអាន ដើម្បីអាន នៅកន្លែងនោះ ឬដើម្បីយកទៅផ្ទះ ព័ត៌មានលំអិតមួយចំនួនរបស់បុគ្គលនោះត្រូវបានកត់ត្រាទុក។ រូបភាពខាងក្រោម បង្ហាញពីចំនួនកត់ត្រាសរុប ដែលត្រូវបានធ្វើឡើង ហើយដែលយើងគណនារកចំនួនអ្នកអានសរុប បើទោះបីជាមនុស្សដដែលអាចត្រូវបានកត់លើសពីមួយដងក៏ដោយ។

តារាង ២១៖ អ្នកអានក្នុងបន្ទប់អាន




ផ្ទុយគ្នានឹងបណ្ណាល័យ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ មានសិស្សអប់រំក្រៅប្រព័ន្ធច្រើនជាងសិស្សសាលាក្នុងប្រព័ន្ធ ដែលមកប្រើប្រាស់បន្ទប់អាន។ នេះអាចដោយសារតែគេងាយស្រួលប្រើប្រាស់បន្ទប់អាននៅក្នុងសហគមន៍ ដែលជារឿយៗ មានទីតាំងនៅក្នុងសាលាភូមិ ឬនៅខាងក្រៅផ្ទះអ្នកណាម្នាក់។ បន្ទប់អានក៏មានភាគរយអ្នកប្រើប្រាស់ជាប្រជាពលរដ្ឋទូទៅខ្ពស់ជាងគេ 8% បើធៀបជាមួយនឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងបណ្ណាល័យ។

សរុបមក មានអ្នកអានចំនួន 4304នាក់ មកពីបន្ទប់អានចំនួន 7 គិតជាមធ្យមមាន 615នាក់ ក្នុងមួយបន្ទប់អាន ដែលស្រដៀងគ្នានឹងបណ្ណាល័យ ដំណើរការដោយអង្គការក្រៅរដ្ឋាភិបាលដែរ ( 612នាក់)។ រដ្ឋាភិបាលមានបន្ទប់អានដែលមានដំណើរការចំនួន 176ដែលមានអ្នកអានសរុបចំនួន 66697នាក់ គិតជាមធ្យមមានអ្នកអានចំនួន 379នាក់។

# វិធីសាស្ត្របង្រៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ

ការស្រាវជ្រាវអំពីវិធីសាស្ត្របង្រៀន មិនមែនជាផ្នែកចាំបាច់របស់ការស្រាវជ្រាវនេះ ហើយក៏មាន មិនកន្លែងនៅក្នុងកម្រងសំណួរ ដើម្បីប្រមូលព័ត៌មាននេះដែរ។ ប៉ុន្តែ វាស្តែងចេញយ៉ាងច្បាស់ចេញពីការ ពិភាក្សាជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល និងអ្នកប្រមូលទិន្នន័យ ក្នុង និងក្រោយពេលធ្វើការស្រាវជ្រាវនេះ ថា អង្គការក្រៅរដ្ឋាភិបាលប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសអប់រំក្រៅប្រព័ន្ធ ដែលទទួលបានពីការបណ្តុះបណ្តាល ដែលផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងដោយស្ថាប័នអប់រំ ឬអង្គការក្រៅរដ្ឋាភិបាលដែលមានបទពិសោធន៍ដទៃទៀត។ អង្គការទាំងនេះប្រើប្រាស់វិធីសាស្ត្រ និងបែបផែនផ្សេងៗពីគ្នា ដើម្បី សម្រប

ទៅតាមស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការសម្រេចទៅតាមគោលដៅនៃការអភិវឌ្ឍមនុស្ស ទៅ តាម លក្ខខណ្ឌរបស់មនុស្ស ៖ ជួយមនុស្សអភិវឌ្ឍសមត្ថភាព ដើម្បីកែលំអជីវភាពរស់នៅរបស់ពួកគេ។

ខណៈពេលដែលវិធីសាស្ត្របង្រៀនក្នុងការអប់រំក្រៅប្រព័ន្ធអាចមានលក្ខណៈខុសគ្នាបន្តិចបន្តួច ឬថ្មីស្រឡាង ចំពោះអ្នកដែលចំណាយពេលវេលាទាំងអស់របស់ខ្លួន នៅក្នុងប្រព័ន្ធអប់រំក្នុងប្រព័ន្ធ  គោលវិធី/  បច្ចេកទេសផ្សេងៗរបស់ការអប់រំក្រៅប្រព័ន្ធត្រូវបានគេយកមកប្រើប្រាស់ ក្នុងរយៈពេលមួយយ៉ាងយូររួចទៅ ហើយនៅក្នុងសង្គមបែបប្រពៃណី នៅក្នុងប្រទេសកម្ពុជា។ នៅតាមភូមិជនបទ និងទីប្រជុំជននានា យុវជន អាចសិក្សារៀនសូត្រ និងអាចធ្វើជាអ្នករៀនអនុវត្តការងារ ដោយប្រើប្រាស់បំណិនជីវិតនានា ដូចជា ត្បាញ កន្ទេល/ត្បាញកន្ទ្រក់ផ្ដៅ សិល្បៈនៃការត្បាញសូត្រ ជាងចម្លាក់ ជាងឈើ ជាងជួសជុលកង់និងម៉ូតូ និងជាងកាត់ដេរ។ ពួកគេបានរៀនសូត្រជំនាញទាំងនេះ តាមរយៈបទពិសោធន៍ផ្ទាល់ ឬការបណ្ដុះបណ្ដាលពេល កំពុងបំពេញការងារជាក់ស្ដែង។ នៅក្នុងសង្គម និងការប្រតិបត្តិវប្បធម៌នៅកម្ពុជា មនុស្សនៅក្នុងភូមិ និងអ្នកដឹកនាំភូមិ ដែលទទួលបានការគោរព ដោយសារតែអាយុ និងកេរ្ដិ៍មរតកបន្សល់ពីជំនាន់មុនៗ បានផ្ទេរបន្តនូវចំណេះដឹង និងបទពិសោធន៍ជាប្រពៃណីរបស់ពួកគេ ដើម្បីធានាយ៉ាងណាឱ្យមនុស្សជំនាន់ក្រោយអាចរៀនសូត្រពីគតិបណ្ឌិតភាពសុខុដុមរមនា និងស្ថិរភាពរបស់ចាស់ព្រឹទ្ធាចារ្យទាំងនេះ។

ក្រាហ្វខាងក្រោមបង្ហាញពីកម្រិតនៃការអប់រំខ្ពស់បំផុត ដែលបញ្ចប់ដោយគ្រូនៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗពីគ្នា។ យើងបានធ្វើការប្រៀបធៀបលទ្ធផលទាំងនេះ ជាមួយនឹងការទទួលបានការអប់រំរបស់បុគ្គលិកបង្រៀន ដូចដែលត្រូវបានកត់ត្រាដោយក្រសួងអប់រំ យុវជន និងកីឡា។ [11] ដូចដែលឃើញ គ្រូនៅ ក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់អង្គការក្រៅរដ្ឋាភិបាល ច្រើនតែមានសញ្ញាបត្រសកលវិទ្យាល័យ បើទោះបី ជាគ្រូដែលបង្រៀននៅក្នុងកម្មវិធីអក្ខរកម្ម/បំណិនជិវិត ច្រើនតែរៀនបានត្រឹមតែបឋមសិក្សាក៏ដោយ។

[11] Department of Planning (2012), 'Education Management Information Statistics 2011-12, Ministry of Education, Youth and Sports

**តារាង២២** ៖ កម្រិតវប្បធម៌ខ្ពស់បំផុត របស់គ្រូបង្រៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ បែងចែកទៅតាមប្រភេទកម្មវិធី




មូលហេតុដែលអាចមានមួយ ដែលនាំឱ្យគ្រូបង្រៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់អង្គការក្រៅរដ្ឋាភិបាល មានសញ្ញាបត្រ គឺដោយសារតែអាយុមធ្យមរបស់គ្រូបង្រៀនទាំងនេះមានកម្រិតទាប ហើយអ្នកដែលមានអាយុក្រោម 35ឆ្នាំ មានឱកាសច្រើន ក្នុងការទៅរៀននៅសកលវិទ្យាល័យ ជាងអ្នកដែលមាន អាយុខ្ពង់ 40 និង50ឆ្នាំ។

ខាងក្រោមនេះគឺជាអាយុមធ្យមរបស់គ្រូ ដែលចូលរួមនៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធ ប៉ុន្តែអាយុ មធ្យមរបស់គ្រូនៅក្នុងវិស័យសាធារណៈក្នុងប្រព័ន្ធមិនត្រូវបានបង្ហាញនៅក្នុងEMISឡើយបើទោះបីជាប្រព័ន្ធព័ត៌មាននេះមានព័ត៌មានអំពីអាយុមធ្យមរបស់នាយកសាលា 46.4 ឆ្នាំក៏ដោយ[12]។ ប៉ុន្តែតួលេខនេះមិនអាចប្រើប្រាស់សម្រាប់ធ្វើការប្រៀបធៀបឱ្យបានសុក្រឹតនោះឡើយ ដោយសារតែការក្លាយខ្លួនជានាយកសាលាជាធម្មតាទទួលរងឥទ្ធិពលដោយសាររយៈពេលនៃការផ្តល់សេវា និងអាយុ ដូច្នេះគេរំពឹងថា នាយកសាលាមានអាយុគិតជាមធ្យមច្រើនជាងគ្រូបង្រៀន។

[12] Department of Planning, EMIS 2011-12, MoEYS

**តារាង២៣ ៖** អាយុគិតជាមធ្យម




ប្រសិនបើគ្រូបង្រៀននៅក្នុងវិស័យអប់រំក្រៅប្រព័ន្ធរបស់អង្គការក្រៅរដ្ឋាភិបាលនៅតែបន្តមានសញ្ញាបត្រនោះនេះអាចជាការបង្ហាញថាអង្គការក្រៅរដ្ឋាភិបាលកំពុងផ្តល់នូវលក្ខខណ្ឌការងារល្អប្រសើរជាងលក្ខខណ្ឌការងារដែលទទួលបានដោយគ្រូរបស់រដ្ឋាភិបាលដែលនាំឱ្យពួកគេអាចទាក់ទាញបុគ្គលិកដែលកាន់តែមានសមត្ថភាពបន្ថែមទៀត។ មនុស្សក៏អាចគិតផងដែរថានៅក្នុងអង្គការក្រៅរដ្ឋាភិបាលមានវិសាលភាពសម្រាប់អភិវឌ្ឍអាជីព និងជំនាញ ច្រើនជាងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ។

ក្រៅពីកម្មវិធីសមមូល ជាមធ្យម គ្រូមិនសូវមានបទពិសោធន៍ឡើយ។ គ្រូដែលបង្រៀននៅក្នុងកម្មវិធីសមមូលមានបទពិសោធន៍ជាមធ្យម 10.1ឆ្នាំ ប៉ុន្តែគ្រូនៅក្នុងកម្មវិធីបំពេញវិជ្ជមានបទពិសោធន៍ 4.67ឆ្នាំ, គ្រូនៅក្នុងកម្មវិធីអក្ខរកម្ម/ជំនាញការងារមានបទពិសោធន៍ជាមធ្យម 3.37ឆ្នាំ ហើយគ្រូនៅក្នុងកម្មវិធីចូលរៀនឡើងវិញមានបទពិសោធន៍តិចតួចជាងគេត្រឹមតែ 3.23ឆ្នាំតែប៉ុណ្ណោះ។

គ្រូក្នុងកម្មវិធីចូលរៀនឡើងវិញ និងសមមូល ត្រូវបានស្នើឱ្យផ្តល់នូវព័ត៌មានអំពីចំនួនថ្ងៃនៃការបណ្តុះបណ្តាល សម្រាប់ការបង្រៀនកម្មវិធី ដែលគ្រូទាំងនេះទទួល។ គ្រូម្នាក់មកពី CAD បានទទួលការបណ្តុះបណ្តាលរយៈពេល15ថ្ងៃអំពីការធ្វើជាគ្រូសម្រាប់កម្មវិធីចូលរៀនឡើងវិញ ហើយគ្រូម្នាក់នៅអង្គការកុមារកំព្រាជនបទ (ROO) បានទទួលការបណ្តុះបណ្តាលជាក់លាក់រយៈពេល 2ថ្ងៃ។ សម្រាប់កម្មវិធីសមមូលវិញគ្រូម្នាក់មកពី CAD បានទទួលការបណ្តុះបណ្តាលរយៈពេល 180ថ្ងៃ ខណៈពេលដែលគ្រូ 3នាក់ ទៀតបានទទួលការបណ្តុះបណ្តាល 5 ថ្ងៃ។ ការប្រមូលទិន្នន័យអំពីចំណុចនេះ នៅមានកម្រិត ដោយសារតែ អង្គការក្រៅរដ្ឋាភិបាលមិនបានរក្សាទុកឯកសារអំពីការបណ្តុះបណ្តាល។

## លទ្ធផលរកឃើញ និងអនុសាសន៍

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថាមានអង្គការចំនួន48ដែលបានផ្តល់កម្មវិធីអប់រំក្រៅប្រព័ន្ធសរុបចំនួន383កម្មវិធីនិងរដ្ឋាភិបាលបានផ្តល់ចំនួន3217កម្មវិធីនៅក្នុងទូទាំងប្រទេសកម្ពុជាយើងក្នុងឆ្នាំ 2012 នេះ ។ តែទោះបីជាយ៉ាងណាក៏ដោយដូចដែលបានពិភាក្សានៅក្នុងផ្នែកនៃសេចក្តីផ្តើមរួចមកហើយថាវាមានហេតុផល 2 យ៉ាងដែលយើងខ្ញុំគិតថាតួរលេខនេះមិនតំនាងចំនួនពិតប្រាកដនៃអង្គការដែលបានផ្តល់សេវាកម្មអប់រំក្រៅប្រព័ន្ធ និងចំនួនសរុបនៃអង្គការទាំងអស់នោះទេ ។ អង្គការមួយចំនួនមានការពិបាកក្នុងការបង្ហាញព័ត៍មានដែលយើងបានស្នើសុំពីពួកគេពីព្រោះថានៅដើមឆ្នាំ 2012 ពួកគេមិនបានដឹងថាយើងនឹងធ្វើការចុះអង្កេតស្រាវជ្រាវដូចនេះ ។ បន្ថែមលើសពីនេះទៅទៀតការយល់មិនច្បាស់លាស់ពាក់ព័ន្ធទៅនឹងតើអ្វីដែលជាសេវាអប់រំក្រៅប្រព័ន្ធនិងអ្វីដែលមិនមែនជាសេវាអប់រំក្រៅប្រព័ន្ធបាននាំអោយអង្គការមួយចំនួនខ្លះមិនគិតថាសកម្មភាពរបស់គេជាសេវាអប់រំក្រៅប្រព័ន្ធនោះឡើយ ។ ជាឧទាហរណ៍:មានភាពមិនច្បាស់លាស់អំពីកម្មវិធីអប់រំក្រៅប្រព័ន្ធមួយដែលមានសិស្សមកពីសាលាក្នុងប្រព័ន្ធនិងកុមារក្រៅសាលាចូលរៀនជាមួយគ្នាថាតើគួចាត់ទុកជាកម្មវិធីអប់រំក្រៅប្រព័ន្ធឬទេ ។ មានការពិភាក្សាលំអិតអំពីបញ្ហានេះនៅក្នុងទំព័រទី 11នៃរបាយការណ៍អង្កេតនេះ ។ ម្យ៉ាងវិញទៀតយើងជឿជាក់ថាមានអង្គការសមាជិកNEPជាច្រើនទៀតបានផ្តល់សេវាកម្មអប់រំក្រៅប្រព័ន្ធនៅតាមខេត្តផ្សេងទៀតដែលយើងមិនបានទៅសំភាសន៍ពួកគេ ដោយសាមិនមានពេលវេលាគ្រប់គ្រាន់ ។

លទ្ធផលរកឃើញសំខាន់មួយទៀតគឺថា មានអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលកំពុងផ្តល់សេវាដល់កុមារដែលមានអាយុក្រោម 15ឆ្នាំ ខណៈពេលដែលគោលនយោបាយរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ផ្តោតគោលដៅលើមនុស្សអាយុ 15-45ឆ្នាំ។ <u>ឧទាហរណ៍:</u> អ្នកដែលបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធី អក្ខរកម្ម 38% មានអាយុក្រោម15ឆ្នាំ ហើយនៅក្នុងកម្មវិធីជំនាញ មុខរបរអ្នកដែលបានចុះឈ្មោះចូលរៀន14% មានអាយុក្រោម15ឆ្នាំ។ នេះបង្ហាញថា មានតម្រូវការយ៉ាងខ្ពស់សម្រាប់កម្មវិធីអក្ខរកម្ម ឬ កម្មវិធីជំនាញ មុរបរពីសំណាក់កុមារ ដែលនៅមានសិទ្ធិរៀននៅក្នុងសាលាក្នុងប្រព័ន្ធ។ គេមិនដឹង ថាតើមានកុមារអាយុក្រោម 15ឆ្នាំប៉ុន្មាននាក់ ក្នុងចំណោមកុមារទាំងនេះ ដែលបានទៅរៀននៅក្នុងសាលាដែរឬអត់នោះទេ។

យើងបានរកឃើញថា កម្មវិធីចំនួន 52% ក្នុងចំណោមកម្មវិធីអប់រំក្រៅប្រព័ន្ធទាំងអស់ចំនួន383 ដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល មានតែនៅក្នុងរាជធានីខេត្ត 3តែប៉ុណ្ណោះ ពោលគឺខេត្តស្វាយរៀង រតនគិរី និងភ្នំពេញ។ ដោយសារតែកម្មវិធី 75% ក្នុងចំណោមកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់អង្គការក្រៅរដ្ឋាភិបាលទាំង អស់ផ្តោតលើអក្ខរកម្ម ឬជំនាញ មុខរបរ គេអាចរំពឹងថា គួរមានកម្មវិធីអប់រំក្រៅប្រព័ន្ធយ៉ាងច្រើននៅក្នុងខេត្តស្វាយរៀង និងរតនគិរី ដែលជាខេត្តស្ថិតក្នុងចំណោមខេត្តក្រីក្រជាងគេ នៅក្នុងប្រទេសកម្ពុជា ហើយមានអត្រាអក្ខរកម្មទាប។ ប៉ុន្តែ ការអង្កេតនេះពិតជាបានបង្ហាញថា មានខេត្តជាច្រើនដែលមានសេវាអប់រំក្រៅប្រព័ន្ធដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលតិចតួចប៉ុណ្ណោះ។ **<u>ឧទាហរណ៍:</u>** ខេត្ត

សៀមរាប ដែលជាខេត្តមួយ ក្នុងចំណោមខេត្តក្រីក្រជាងគេ ហើយដែលមានមនុស្សជាច្រើនមានកម្រិតជំនាញ និង កម្រិតវប្បធម៌ទាប ដែលផ្លាស់ទីពីកន្លែងផ្សេងទៅរកការងារធ្វើនៅទីនោះ មានកម្មវិធីអប់រំក្រៅប្រព័ន្ធតែ 8 កម្មវិធីតែប៉ុណ្ណោះ។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល គួរដាក់បញ្ចូលព័ត៌មាននានាជាមួយគ្នា ដើម្បីកំណត់ឱ្យដឹងថាតើខេត្តណាខ្លះដែលមានកម្មវិធីអប់រំក្រៅប្រព័ន្ធតិចតួច ហើយអាចមានតម្រូវការខ្ពស់សម្រាប់កម្មវិធីទាំងនេះ។

ដូចដែលត្រូវបានកត់សម្គាល់ខាងលើ កម្មវិធីអប់រំក្រៅប្រព័ន្ធ 75% ក្នុងចំណោមកម្មវិធីទាំងអស់ ដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ផ្តោតសំខាន់លើអក្ខរកម្ម ( 44%) និងជំនាញ មុខរបរ ( 31%)។ យើងស្វាគមន៍ចំពោះការផ្តល់អាទិភាពបែបនេះ ដោយសារតែវាអាចជួយដល់វឌ្ឍនភាព ក្នុងការឈានទៅសម្រេចអត្រាអក្ខរកម្ម 92% សម្រាប់មនុស្សអាយុ 15-24ឆ្នាំ នៅក្នុងឆ្នាំ 2013-14 ដូចដែលត្រូវបានកំណត់ជាគោលដៅនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ 2009-2013របស់ប្រទេសកម្ពុជា។ ប៉ុន្តែមានមនុស្សដែលបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអក្ខរកម្មរបស់អង្គការក្រៅរដ្ឋាភិបាលតែ **36%** ប៉ុណ្ណោះដែលមានអាយុចន្លោះពី 15ដល់ 24ឆ្នាំ ។ បន្ថែមលើសពីនេះទៅទៀតអត្រាបញ្ចប់កម្មវិធីអក្ខរកម្មមានចំនួនទាបគួរអោយព្រួយបារម្ភណ៍ត្រឹមតែ50%ប៉ុណ្ណោះសម្រាប់ក្រុមមុខសញ្ញានេះ ។ យើងបានផ្តល់អនុសាសន៍ថាគប្បីធ្វើការពិនិត្យមើលឡើងវិញនូវសៀវភៅសិក្សាគោលក្នុងកម្មវិធីអក្ខរកម្មដែលបាននិងកំពុងប្រើប្រាស់សព្វថ្ងៃ ដើម្បីធ្វើអោយជឿជាក់ប្រាកដថាវាមានភាពពាក់ព័ន្ធគ្នាទៅនឹងក្រុមអាយុនិងតម្រូវការរបស់សហគមន៍ជាក់ស្តែង ។

គេអាចចាត់ទុកថាជាការភ្ញាក់ផ្អើលមួយ ដោយសារតែមានមជ្ឈមណ្ឌលសិក្សាសហគមន៍តែ 23កន្លែងប៉ុណ្ណោះ ដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែមានបណ្ណាល័យចំនួន 22 និងបន្ទប់អានចំនួន 7 ដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល។ ការស្រាវជ្រាវរបស់យើងបានរកឃើញថា មុខងារ និងសម្ភាររូបវន្តរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងបន្ទប់អាន មានលក្ខណៈស្រដៀងគ្នា <u>ឧទាហរណ៍</u>: ទីកន្លែងទាំងនេះភាគច្រើនមានបន្ទប់ប្រជុំ និងមានបន្ទប់រៀន ហើយបណ្ណាល័យ ឬបន្ទប់អានច្រើនតែមានកុំព្យូទ័រ ឬទូរទស្សន៍/វិទ្យុ សម្រាប់ប្រើប្រាស់ដូចមជ្ឈមណ្ឌលសិក្សាសហគមន៍ដែរ។ ភាពខុស ប្លែកគ្នាតែមួយគត់ គឺប្រភេទអគារដែលមាន។ ប្រសិនបើយើងបូកសរុបចំនួនទីកន្លែងទាំង 3 ប្រភេទនេះ យើងរកឃើញថា មានមជ្ឈមណ្ឌលសិក្សាសហគមន៍/បណ្ណាល័យ /បន្ទប់អានចំនួន52កន្លែងដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល។ ប៉ុន្តែការបង្កើនចំនួននេះបន្ថែមទៀតគួរតែ ជាគោលដៅផ្តោតសំខាន់របស់អង្គការក្រៅរដ្ឋាភិបាលនាពេលអនាគត ជាមួយការពិចារណាបន្ថែមចំនួន២ខាងក្រោមនេះ៖

អង្គការក្រៅរដ្ឋាភិបាល ដែលអនុវត្តមជ្ឈមណ្ឌលសិក្សាសហគមន៍ គួរពិចារណាលើអ្នកដែលកំពុងប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍របស់ពួកគេ។ យើងបានរកឃើញថា មានសិស្សសាលា ដែលប្រើប្រាស់ឯកសារអាននៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ច្រើនជាងសិស្សអប់រំក្រៅប្រព័ន្ធដល់ទៅ9ដង ។ ប្រសិន

បើយើងមិនគិតពីប្រភេទទាំងពីរនេះទេ ចំនួនប្រជាពលរដ្ឋទូទៅ ដែលប្រើប្រាស់ឯកសារអាន នៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ មានកម្រិតទាបបំផុត ត្រឹមតែ 4% ប៉ុណ្ណោះ។ ហើយ ប្រភេទអគារ និង លទ្ធភាពទទួលបានសេវា ហាក់បីដូចជាធ្វើឱ្យមានភាពខុសប្លែកគ្នាចំពោះអ្នក ដែលប្រើប្រាស់ទីតាំងរូបវ័ន្ត នេះ។

បន្ទប់អាន ដែលជារឿយ ស្ថិតនៅតាមផ្ទះរបស់ប្រជាពលរដ្ឋ ឬនៅក្នុងសហគមន៍ ដែលមានម៉ោងចូលអានបត់បែន និងមិនសូវមានបទបញ្ញាតឹងរ៉ឹង ទទួលបានជោគជ័យច្រើនបំផុត ក្នុងការទាក់ទាញសិស្សអប់រំក្រៅប្រព័ន្ធ និងប្រជាពលរដ្ឋទូទៅ។ អ្នកប្រើប្រាស់បន្ទប់អាន 49% គឺជាសិស្សអប់រំក្រៅប្រព័ន្ធ និង 8% ជាប្រជាពលរដ្ឋទូទៅ។ ដោយឡែកសម្រាប់បណ្ណាល័យវិញ 41% ជាសិស្សអប់រំក្រៅប្រព័ន្ធ និង 5% ជាប្រជាពលរដ្ឋទូទៅ ហើយចំពោះមជ្ឈមណ្ឌលសិក្សាសហគមន៍ មានតែ 9% ប៉ុណ្ណោះជាសិស្សអប់រំក្រៅប្រព័ន្ធ និង 4% ជាប្រជាពលរដ្ឋទូទៅ។ នេះសរបញ្ជាក់ថា ប្រសិនបើអង្គការក្រៅរដ្ឋាភិបាល ឬរដ្ឋាភិបាលចង់ផ្តោតលើប្រជាពលរដ្ឋទូទៅ ឬលើសិស្សអប់រំក្រៅប្រព័ន្ធ ភាពបត់បែនរបស់បន្ទប់អានហាក់បីដូចជាមានជោគជ័យជាងគេ។ លើសពីនេះ ក៏មានវិសាលភាពសម្រាប់ឱ្យមានការរីកចម្រើនជាងនេះផងដែរ ដោយសារតែមានអង្គការក្រៅរដ្ឋាភិបាលតែ3 ប៉ុណ្ណោះ ដែលមានបន្ទប់អានសរុបចំនួន 7 ។

បើទោះបីជាកុមារដែលបានបោះបង់ចោលការសិក្សាមានចំនួនច្រើនយ៉ាងណាក៏ដោយ មានអង្គការក្រៅរដ្ឋាភិបាលតែ4 ប៉ុណ្ណោះ ដែលអនុវត្តកម្មវិធីចូលរៀនឡើងវិញសរុបចំនួន 10កម្មវិធី។ លើសពីនេះទិន្នន័យរបស់យើងបង្ហាញថាកម្មវិធីចូលរៀនឡើងវិញអាចមិនបានផ្តោតលើកុមារដែលបានបោះបង់ចោលការសិក្សាប៉ុន្តែផ្តោតលើកុមារដែលត្រូវការការគាំទ្របន្ថែម ដើម្បីអាចឡើងទៅរៀននៅថ្នាក់បន្ទាប់វិញ។ នេះក៏ជាលទ្ធផលរកឃើញបឋមរបស់ការស្រាវជ្រាវមួយ ដែលធ្វើឡើងដោយយូណេស្កូផងដែរ។ [13] កម្មវិធីចូលរៀនឡើងវិញគួរកត់ត្រាឱ្យដឹងថាតើមានសិស្សដែលចូលរៀនក្នុងកម្មវិធីនេះប៉ុន្មាននាក់ ដែលជាសិស្សបោះបង់ចោលការសិក្សា។

ចំនួនកម្មវិធីសមមូល នៅមានកម្រិតទាប (28) ជាពិសេស នៅពេលដែលពុំមានកម្មវិធីសមមូល របស់រដ្ឋាភិបាល។ ចាំបាច់ត្រូវបញ្ចប់កម្មវិធីសិក្សាសមមូល និងសៀវភៅសិក្សាសម្រាប់កម្រិតមធ្យមសិក្សា បឋមភូមិ និងធ្វើបច្ចុប្បន្នសៀវភៅសិក្សាសម្រាប់បឋមសិក្សា ដើម្បីឆ្លើយតបទៅនឹងកម្មវិធីសិក្សាក្នុងប្រព័ន្ធ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មកន្លងមក។ ការបង្កើតនូវគោលការណ៍ណែនាំសម្រាប់ជ្រើសរើសគ្រូសមមូល ក៏ នឹងជួយដល់អង្គការក្រៅរដ្ឋាភិបាលនានា ដែលចង់អនុវត្តកម្មវិធីសមមូលផងដែរ។ អង្គការក្រៅរដ្ឋាភិបាលក៏ បានរាយការណ៍ផងដែរថា ការពិនិត្យតាមដានរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធលើវគ្គសិក្សារបស់ពួកគេ មិនត្រូវបានធ្វើឡើងញឹកញាប់ឡើយ ដែលធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលនានាមានការលំបាក ដើម្បីមានឯកសារផ្លូវការ ដែលអាចជួយឱ្យសិស្សត្រឡប់មករៀនក្នុងសាលាក្នុងប្រព័ន្ធវិញបាន។

[13] Arakawa, N (2013), Presentation to Education Sector Working Group, Cambodia. 21st Jan 2013

បើតាមការពិភាក្សាជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនានា  អង្គការក្រៅរដ្ឋាភិបាលទាំងនេះ ស្វាគមន៍ចំពោះការបង្កើនភាពបត់បែន ក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីអ្វី ដែលចាត់ទុកថាជាសេវាអប់រំ ក្រៅប្រព័ន្ធ ដែលនឹងជួយពួកគេឱ្យផ្តល់សេវា ដែលនឹងបំពេញទៅតាមតម្រូវការរបស់សហគមន៍ពួកគេកាន់ តែប្រសើរជាងមុន។ មានកង្វះការយល់ដឹងរួមគ្នារវាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គការក្រៅ រដ្ឋាភិបាលអំពីអ្វីដែលជាសេវាអប់រំក្រៅប្រព័ន្ធ និងអ្វីដែលមិនមែនជាសេវាអប់រំក្រៅប្រព័ន្ធ។ លើសពីនេះ អង្គការក្រៅរដ្ឋាភិបាលចង់បានភាពបត់បែនច្រើនជាងមុនអំពីឯកសារ និងវិធីសាស្ត្រសម្រាប់ប្រើប្រាស់ នៅ ពេលផ្តល់សេវាអប់រំក្រៅប្រព័ន្ធ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនចង់ប្រើប្រាស់ឯកសារទាំងឡាយណា ដែលមិនផលិតដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ហើយដែលអាចមានបច្ចុប្បន្នភាពជាងមុន ៕

**ឧបសម្ព័ន្ធ៖** *ឈ្មោះអង្គការដែលបានផ្តល់កម្មវិធីអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ 2012*

| ឈ្មោះអង្គការ | ចំនួនកម្មវិធីដែលបានផ្តល់ដោយអង្គការនីមួយៗ | | | | | |
|---|---|---|---|---|---|---|
| | អក្ខរកម្ម | ជំនាញមុខរបរ | ចូលរៀនឡើងវិញ | សមមូល | បំពេញវិជ្ជា | ម.ស.ស/ បណ្ណាល័យ / បន្ទប់អាន |
| ADRA Cambodia | 36 | | | | | |
| AFESIP | 4 | 4 | | | | |
| Buddhism and Society Development Association (BSDA) | | | | | | 2 |
| The Cambodian Center for the Protection of Children's Rights (CCPCR) | 3 | 6 | | | | 1 |
| Cambodia Children's Advocacy Foundation (CCAF) | 15 | | | | | |
| Catholic | | | | | | 3 |
| CCS | | | 4 | | | 1 |
| Child Fund Cambodia | 12 | 12 | | | | 12 |
| ឈ្មោះអង្គការ | ចំនួនកម្មវិធីដែលបានផ្តល់ដោយអង្គការនីមួយៗ | | | | | |

| | អក្ខរកម្ម | ជំនាញមុខរបរ | ចូលរៀនឡើងវិញ | សមមូល | បំពេញវិជ្ជា | ម.ស.ស/បណ្ណាល័យ / បន្ទប់អាន |
|---|---|---|---|---|---|---|
| Children Action for Development (CAD) | | 1 | 3 | 3 | | 1 |
| Children of Hope | | 6 | | | | |
| Community Council for Development (CCD) | | | | | | 1 |
| Caring for Young Khmer (CYK) | | 23 | | | | |
| Damnok Toek/ Goutted' Eau Cambodia | | 1 | | 6 | | 1 |
| Disability Development Services Program (DDSP) | 3 | 1 | | | | |
| Donbosco | | | | | 6 | |
| The Foundation for Developing Cambodian Communities (FDCC) | | | | | | 1 |
| Friends/ Mithsamlanh | 1 | 12 | | 7 | | 5 |
| HTCC | | 3 | | | | |
| International Cooperation for Cambodia | 27 | | | | | |

| ឈ្មោះអង្គការ | ចំនួនកម្មវិធីដែលបានផ្តល់ដោយអង្គការនីមួយៗ | | | | | |
|---|---|---|---|---|---|---|
| | អក្ខរកម្ម | ជំនាញមុខរបរ | ចូលរៀនឡើងវិញ | សមមូល | បំពេញវិជ្ជា | ម.ស.ស/ បណ្ណាល័យ / បន្ទប់អាន |
| JWI | | 3 | | | | |
| KADO | | | | | | 1 |
| Khmer New Generation | | 8 | | | | |
| KnK Cambodia | | 5 | | | | 1 |
| Mekong Plus | | 5 | | | | |
| M'lopTapang | 2 | 1 | | 4 | | 4 |
| National Federation of UNESCO Associations in Japan | 1 | | | | | |
| Neighbours of Cambodia | 1 | | | | | |
| NIF | | 1 | | | | |
| Non-Timber Forest Products Organization | 15 | | | | | 7 |
| OEC (Operatios Enfants du Cambodge) | 10 | | | | | |
| One in love Ministry (OILM) | 1 | | 1 | | | |
| ឈ្មោះអង្គការ | ចំនួនកម្មវិធីដែលបានផ្តល់ដោយអង្គការនីមួយៗ | | | | | |

| | អក្ខរកម្ម | ជំនាញមុខរបរ | ចូលរៀនឡើងវិញ | សមមូល | បំពេញវិជ្ជា | ម.ស.ស/បណ្ណាល័យ / បន្ទប់អាន |
|---|---|---|---|---|---|---|
| Our Home NGO | | 1 | | | | |
| PTE (Por Thom Elderly) | 10 | 2 | | | | |
| Protect the Earth Protect Yourself (PEPY) | | | | 1 | | 1 |
| Promvitheathor (PVT) | | 3 | | | | |
| Pour un Sourire d'Enfant (PSE) | | | | | | 1 |
| Rabbit School | 2 | | | | | |
| Respect for Children | | | | 2 | | |
| Rural Aid Organisation (RAO) | 7 | | | | | |
| Rural Economic Development Association (REDA) | | 5 | | | | |
| Rural Orphan Organization (ROO) | | 4 | 2 | | | |
| Salarien Kampuchea | | | | | | 2 |
| ឈ្មោះអង្គការ | ចំនួនកម្មវិធីដែលបានផ្តល់ដោយអង្គការនីមួយៗ | | | | | |

| | អក្ខរកម្ម | ជំនាញមុខរបរ | ចូលរៀនឡើងវិញ | សមមូល | បំពេញវិជ្ជា | ម.ស.ស/ បណ្ណាល័យ / បន្ទប់អាន |
|---|---|---|---|---|---|---|
| Sok Keo Chan Sarun | | 1 | | | | 2 |
| Starfishes | | | | 5 | | |
| This Life Cambodia | | 2 | | | | |
| Welt-Hunger-Hilfe (WHH/GAA) | 16 | | | | | 3 |
| Women Development Association | 2 | 9 | | | | |
| Youth Resource Development Programme (YRDP) | | | | | | 2 |

# Bibliography

Arakawa, N. (2013, January 21). Re-entry Review. *UNESCO presentation at the Education Sector Working Group* . Phnom Penh: Meeting attended by Gordon Conochie.

Broderick, D. &. (2011, August 11). *Open Editorial by the UN Resident Coordinator in Cambodia and Director of the International Labour Organisation in Cambodia*. Retrieved January 25, 2012, from United Nations: http://www.un.org.kh/index.php?option=com_content&view=article&id=460:international-youth-day-empowering-cambodias-youth-&catid=47:features&itemid=88

Department of Non Formal Education. (2013, January 29). Meeting handout. Phnom Penh: Meeting attended by Lay Vutha.

Department of Non-Formal Education. (2008). *CONFINTEA VI: Rapport national soumis par le gouvernement de Cambodge.* Phnom Penh: Ministry of Education, Youth and Sport.

Department of Non-Formal Education. (2002). *Policy of Non-Formal Education.* Phnom Penh: Ministry of Education, Youth and Sports.

Department of Planning. (2012). *Education Management Information Statistics 2011/12.* Phnom Penh: Ministry of Education, Youth and Sports.

EFA Global Monitoring Report. (2011). *The Hidden Crisis: Armed Conflict and Education.* Paris: UNESCO.

Haddad. (2007). *Strengthening Community Learning Centres through Linkages and Networks.* Bangkok: UNESCO.

National Institute of Statistics. (2008). *General Population Census of Cambodia.* Phnom Penh: The Royal Government of Cambodia.

# សេចក្តីថ្លែងអំណរគុណ

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល(NEP)សូមថ្លែងអំណរគុណយ៉ាងខ្លាំងដល់អង្គការយូណេស្កូប្រចាំនៅភ្នំពេញដែលបានផ្តួចផ្តើមអោយមានការចុះអង្កេតស្រាវជ្រាវនេះឡើង ព្រមទាំងបានផ្តល់នូវថវិកាដើម្បីអោយយើងខ្ញុំអាចចញ្ចប់រាល់កិច្ចការទាំងអស់នេះ ។ ជាពិសេសសូមថ្លែងអំណរគុណដល់លោកស្រី Naoko Arakawa និងលោក យិន សៀងសូម៉េត នៃអង្គការយូណេស្កូដែលបានផ្តល់នូវយោបល់និងការណែនាំដ៏មានតម្លៃដែលពិតជាជួយយ៉ាងធំធេងដល់យើងខ្ញុំដើម្បីអាចបញ្ចប់នូវរបាយការណ៏នេះ ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់អង្គការនិងមន្ត្រីចុះប្រមូលទិន្នន័យព័ត៏មានទាំងអស់ដែលបានខិតខំបំពេញការងារយ៉ាងយកចិត្តទុកដាក់និងប្រឹងប្រែងអស់ពីកំលាំងកាយចិត្តប្រមូលយកព័ត៏មានបានទាន់ពេលវេលា ។

ជាទីបញ្ចប់ក៏សូមថ្លែងអំណរគុណដល់គ្រប់បុគ្គលិកអង្គការទាំងអស់ដែលបានចូលរួមផ្តល់នូវព័ត៏មានប្រកបដោយភាពអាចជឿទុកចិត្តបានដល់យើងខ្ញុំ ។ ប្រសិនបើគ្មានការចូលរួមដោយស្មោះសពីលោកលោកស្រីទេនោះ របាយការណ៍នេះពិតជាមិនអាចចេញជារូបរាង្គឡើងទេ ។

© អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល

© NGO Education Partnership (NEP), 2013

NGO Education Partnership is a membership organization that promotes active collaboration between NGOs working in education and advocates on behalf of its member organizations in policy meetings and discussions with the Ministry of Education Youth and Sports (MoEYS) in Cambodia. Over 100 educational NGOs working in Cambodia are members of NEP.

This report is available at: www.nepcambodia.org